# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ២៣ ខែមីនា លេខ ៣

ព. ស. ២៤៩៣ – គ. ស. ១៩៥១

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
|---|---|---|
| ពុទ្ធសាសនានិងត្រៃរ័ត្នសាសនា (សន្និសីទលោកវេជ្ជបណ្ឌិតម៉ីត្តូត៍) | លោក ភ៊យ - ប៊ុក | ១៦៣ |
| ពន្លឺអាស៊ីទ្វីប (តមក) | លោក ភ៊យ - ប៊ុក | ១៦៩ |
| ធម្មបរិយាយ | ព្រះគ្រូញាណលិខិត កៅ - ស៊ុម | ១៧៧ |
| **ផ្នែកអក្សរសាស្ត្រ** | | |
| ការបណ្ដុះនិស្ស័យ (តមក) | ព្រះមហាឧត្ដមវិជ្ជា រ៉ុង - ប៉ម | ១៨៥ |
| សព្វវចនានុក្រមប្រែជាខ្មែរ (តមក) | លោក ម៉ុញ - តាត្រី | ១៩៣ |
| រឿងព្រេងភូមា (តចប់) | - សាង - សាភ៊ត | ១៩៨ |
| រឿងសាមកុក (តៈក) | - គួ - កន | ២០៧ |
| ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក) | - ឈឹម - ក្រសេម | ២២១ |
| **កំណត់ទីងព្រឹត្តិការណ៍** | | |
| អនុស្សាវរីយ៍ទូរៈមហាសន្និបាត (តចប់) | ពុទ្ធសាសនបណ្ឌិត្យ | ២២៥ |


មួយឆ្នាំមាន ១២ សៀវភៅ ជំនៀជារ .............. ១៤៥៛,០០

# KAMBUJASURIYA

Revu religieuse et littéraire éditée par l'Institut Bouddhique.

## TABLE DES MATIÈRES


| PARTIE RELIGIEUSE | | Pages |
|---|---|---|
| Bouddhisme et Christianisme (Conférence du Docteur André Migot) | M. RAY-BUC . . . . . . . . . | 163 |
| La Lumière de l'Asie (suite) . . . . | M. RAY-BUC . . . . . . . . . | 169 |
| Dhammapariyayakatha. . . . . . . . . . . | PRÉAH KROU KAO-SIM . . . . | 177 |
| **PARTIE LITTERAIRE** | | |
| L'Education morale (suite). . . . . | PREAH MOHA PEUNG-PAM . . | 185 |
| Recueil des mots traduits par la Commission Culturelle (suite) . | M. MENH-NAKRY . . . . . . . | 193 |
| Contes birmans (suite et fin) . . . | M. SANG-SAVAT . . . . . . . . | 198 |
| Histoire de SAMKOK (suite) . . . . | OKNHA NOU-KAN . . . . . . | 207 |
| Histoire du Royaume du Cambodge (suite) . . . . . . . . . . . . . . . . . . | OKNHA CHHIM-KRASEM . . . | 221 |
| **NOTES ET CHRONIQUES** | | |
| Réunion annuelle des religieux du Cambodge (suite et fin) . . . . . | INSTITUT BOUDDHIQUE . . . . | 225 |


Prix d'abonnement annuel comprenant 12 numéros: 145$00

# ពុទ្ធសាសនា និង គ្រិស្តសាសនា

## សន្និសិទលោកមីគូត៍

លោក ប៉ាយ-ប៊ុក ក្រមការនៅពុទ្ធសាសនបណ្ឌិត្យភ្នំពេញ

ប្រែពីទស្សនាវដ្ដី "ហ្វ្រង់អាស៊ី" ខែមិថុនាឆ្នាំ ១៩៥០

(តមក)

---

ខ្ញុំមានប្រាថ្នាចង់ពិសោធន៍ត្រង់ការពណ៌នាដោយសង្ខេប នូវព្រះពុទ្ធសាសនាដែលស្ថិតនៅក្នុងសម័យបច្ចុប្បន្ន ព្រមទាំងគោលការណ៍សំខាន់ៗនៃសាសនានោះនិងរស្មីផ្សាយចេញទៅកាន់មនុស្សជាតិ បង្ហាញឲ្យឃើញនូវមតិពុទ្ធសាសនាខាងផ្លូវលោក តើខុសគ្នាយ៉ាងណាខ្លះ ចំពោះមតិខាងផ្លូវលោក ដែលមាននៅបច្ចិមប្រទេស, ប្រៀបធៀបនូវវិធីការដោះស្រាយពុទ្ធសាសនា និងគ្រិស្តសាសនានូវឧត្តមបញ្ហានៃមនុស្សជាតិ ព្រមទាំងពិសោធន៍នូវឡាក់គោលដែលមានសារៈប្រយោជន៍និងប្រពៃណីសំរិទ្ធិសម្រាំងបញ្ចេញឲ្យឃើញជាក់ស្តែង ធម៌ព្រហ្មវិហារដែលជាអាត្ម័នប្រកបដោយចលនភាពនិងកម្មិកភាពដ៏ក្លាហាននៃសាសនាទាំងពីរ ដែលបានផ្ទេរដម្លៃទៅឲ្យជនជាតិមនុស្សព្រមទាំងទេវតាឥន្ទព្រហ្មទាំងអស់ ។

ខ្ញុំមានបំណងនឹងបញ្ជាក់នូវរឿងរ៉ាវមួយដែលលោកអ្នកយល់ថាជាការមិនប្រសើរ តែមិនមែនជាឥតប្រយោជន៍គឺរឿងព្រះពុទ្ធ ។ មិនមែនជាបុគ្គលកើតដោយទេវឫទ្ធិ ដែលប្រជាជនខាងបូព៌ាអាស៊ីទ្វីបប្រឌិតឡើងដោយ

មនោគតិនោះទេ ៗ តាមដែលពិត ព្រះអង្គជាមហាបុរសមួយដែលប្រវត្តិ-សាស្ត្របានចារឹកព្រះនាមទុកមក, រស់នៅក្នុងប្រទេសឥណ្ឌាខាងជើង ក្នុងសតវត្សទី ១៦ មុនគ្រិស្តសករាជ, ហើយមានជីវភាពពិតប្រាកដ ដូចជាព្រះគ្រិស្ត ឬព្រះមហាម៉ាត ៗ ជីវភាពរបស់ព្រះអង្គ បណ្ឌិតទាំងឡាយបានពិនិត្យទុកគ្រប់ប្រទេស, បើខ្ញុំពោលជាថ្មីទៀតជាការមិនជាប្រយោជន៍ គឺជីវភាពបឋមនិងកណ្តាលនៃព្រះអង្គជាជីវភាពនៃបណ្ឌិត ឬជាធម្មកថិកប្រកបដោយសាមញ្ញលក្ខណៈ ត្រាច់ដើរទេសនាតាមភូមិភាគនិគមជនបទ ប្រៀបដូចជាព្រះគ្រិស្ត ៗ ជីវភាពជាអវសាននៃព្រះពុទ្ធនិងពណ៌នាដោយឡែកផ្សេងពីទីនេះ ៗ លទ្ធិទាំងពីរគឺពុទ្ធសាសនានិងគ្រិស្តសាសនាពិតមែនមានបុព្វហេតុជាសាមញ្ញ តែជាសាសនាមានគេនិយមរាប់អានគោរពពេញលោក ទៅជាសាសនាសកលលោកទាំងពីរ ដែលមានឥទ្ធិពលអាចបែងចំណែកពិភពលោកសត្វ ៗ ខ្លួន ៗ

ជីវភាពសាមញ្ញនេះ មិនអាចធ្វើឲ្យមនុស្សលោកមានជាតិខាងបូព៌ាប្រទេសជាដើម ដែលមានអធ្យាស្រ័យត្រូវការខាងអច្ឆរិយភាពពេញចិត្តទៅបាន ៗ ពួកអ្នកនិពន្ធបាននាំរឿងនេះទៅរចនាដោយនិទានវចនៈប្រកបដោយឥទ្ធានុភាពអស្ចារ្យ ហើយក្នុងសតវត្សទី ៥ ក្រោយមក និទានខ្លះទាំងនេះគេបានយើញយកទៅបញ្ចូលក្នុងរឿងព្រេងព្រះគ្រិស្ត ៗ ការដែលមាតាធម៌ (Saint Esprit) ចុះទៅចាប់បដិសន្ធិក្នុងឧទរព្រះនាង

មារ៉ស្ត្រីព្រហ្មចារិនី ហើយការបដិសន្ធិប្រកបដោយបុទ្ធានុភាពអស្ចារ្យនូវព្រះគ្រិស្ត, ប៉ះប្រៀបធៀបទៅដូចគ្នានឹងព្រះពុទ្ធ កាលចុះពាកស្ថានតុសិតមកចាប់បដិសន្ធិក្នុងឧទរព្រះនាងមហាមាយាទេវីដ៏បរិសុទ្ធិស្អាត ។ ព្រះមហាក្សត្រិយ៍នៅប្រទេសមេដ៍ឬពែរ្ស (Médes ou Perses) សរសើរ ព្រះគ្រិស្តដែលទើបប្រសូតមកថាដូចគ្នានឹងទេវតាឥន្ទព្រហ្ម ដែលចុះមកធ្វើគារវកិច្ចចំពោះព្រះសិទ្ធត្ថកុមារ ។ ពួកអារក្សបិសាចទៅផ្តាញ់ព្រះគ្រិស្តនៅវាលរហោស្ថាន ក៏ដូចគ្នានឹងពួកមារពលពលព្រមទាំងសេនានៃមារចូលមកផ្តាញ់ព្រះបរមពោធិសត្វ មុននឹងបានត្រាស់ដូវអនុត្តរសម្មាសម្ពោធិញ្ញាណ ។ គេអាចពណ៌នាលើកឧទាហរណ៍មកប្រៀបធៀបបុទ្ធិព្រះពុទ្ធនឹងបុទ្ធិព្រះគ្រិស្ត ដោយអនេកបរិយាយ តែយើងយល់ថាមិនមែនជារឿងមានសារៈសំខាន់អ្វីឡើយក្នុងទីនេះ ។

នេះមិនមែនឲ្យយល់តាមការពិត ថាបុទ្ធិដែលចារ៉កនុកក្នុងរឿងរ៉ាវព្រះគ្រិស្តជារឿងចំឡងមកពីបុទ្ធិព្រះពុទ្ធនោះទេ ; គឺរឿងរ៉ាវទាំងនេះជាហេតុឲ្យយើងឃើញថាវិវត្តន៍ខាងផ្លូវប្រាជ្ញារបស់មនុស្ស មិនថានៅប្រទេសណាសុទ្ធតែមានសភាពដូចគ្នាទាំងអស់ ។ មនុស្សក្នុងលោកសន្និវាសនេះមិនអាចនឹងយល់ច្បាស់ថា បុគ្គលប្រកបដោយសន្តិភាពដូចជាព្រះពុទ្ធឬព្រះគ្រិស្តអាចបដិសន្ធិដូចបុគ្គលសាមញ្ញនោះឡើយ ។

មួយទៀត បើគេត្រូវការនិទានរឿង ដោយហេតុថារឿងនោះជាបឋមវត្ថុធាតុនៃរឿងព្រេងទាំងអម្បាលម៉ាន រឿងព្រេងនោះអាចបង្ហាញនូវគំនិតដ៏វិសេស នៃសច្ចធម៌ជានិទានវចនៈប្រកបដោយវិចារណញ្ញាណនោះទៅទៀត ។ តាមករណីនៃជនជាតិឥណ្ឌា ពួកសាសនិកជនយល់ថា រឿងអាទិទេព (divine) ចូលទៅស្ថិតមិនត្រឹមតែស្នាមគំនូសដែលផ្ដិតជាប់នៅនឹងខួរក្បាលនៃប្រជារាស្ត្រ ថែមទាំងផ្ដិតជាប់មាំក្នុងសច្ចៈសម្ភារៈនៃការប្រសិទ្ធិឲ្យនាមអាទិទេព ចុះមកចាប់បដិសន្ធិក្នុងរូបមនុស្សផងទៀត៖ គំនិតទាំងពីរបែបនេះមានសភាពពិតដូចគ្នា ព្រោះថាសច្ចធម៌ទូទៅជាអាទិទេព ។

* * *

ពិតមែនតែព្រះពុទ្ធសាសនាបានពណ៌នាទៅតាមន័យជាបរមត្ថដោយសម្បូណ៌ភាពពិសេស តែគង់មានគតិសំខាន់ ។ ជាមូលដ្ឋានដែលមានបុព្វហេតុជាស្ថាពរគឺការពិសោធន៍ជាសាកលថា សត្វលោកកើតមកមានទុក្ខ ។ ក្នុងមួយជីវភាពនៃព្រះពុទ្ធព្រះអង្គព្យាយាមស្វែងរកហេតុដែលកើតទុក្ខនោះ ដោយព្រះប្រាជ្ញាញាណ; កិច្ចការដែលពិចារណារកហេតុផលគឺកម្ម, អនិច្ចតាធម៌, អនត្តាធម៌មានវិចារណញ្ញាណតែមួយយ៉ាង គឺស្រាវជ្រាវរកដើមកំណើតនៃទុក្ខ ដើម្បីនឹងរកឱសថណាដែលអាចបំបាត់នូវទុក្ខនោះបាន ។

បញ្ហានេះ ពួកពុទ្ធសាសនិកជនសឹងតែពេញចិត្តស្រាវជ្រាវរាវរកគ្រប់ៗគ្នា ។ មានពុទ្ធសាសនិកជនខ្លះយល់ថាទុក្ខមិនមាន, ខ្លះថាទុក្ខនោះត្រូវតែទទួលខាតមិនបាន ។ ចំណែកពួកក្រជាងយល់ថាទុក្ខជាសភាពកើតមកអំពីអាទិទេព ហើយអាទិទេពមានគុណសម្បត្តិដ៏វិសេសវិសាលដើម្បីនឹងធ្វើអានុភាពនៃទុក្ខនោះឲ្យថយចុះ ។ តែកិច្ចការទាំងនេះយើងលំបាកនឹងយល់ពន់ពេក ហើយបើយើងចង់ដឹងថាការណ៍លំបាកដោយពិតនោះយ៉ាងណា យើងត្រូវពិនិត្យសួរដល់ពួកអ្នកប្រាជ្ញខាងអាទិទេព-វិទូ (Thèologien) ដែលព្យាយាមរកមធ្យោបាយដោះស្រាយនូវបញ្ហាទុក្ខដែលផុះផុលឡើងជានិរន្តរកាលមិនចេះដាច់ស្រេច ។ ហេតុម្ដេចបានជាអាទិទេពមានព្រះទ័យប្រកបដោយមហាសប្បុរសនឹងពលភាព អាចបណ្ដាយឲ្យទុក្ខមានដល់បុគ្គលដែលបរិសុទ្ធ? ហេតុម្ដេចបានជាអាទិ-ទេពនោះបង្គាប់ឲ្យមនុស្សទាំងនោះស្ពាយនូវបុព្វកម្មដ៏លាមកជាអនន្តកាលដោយមនុស្សនោះគ្មានប្រព្រឹត្តបាបអកុសលសោះឡើយ? ហេតុម្ដេចក៏អាទិទេពនោះអាចបើកអាកប្បកិរិយាស្រោចស្រង់មនុស្សខ្លះ ឲ្យបានសុខស្រួលជាអនន្តកាល ហើយដាក់ទណ្ឌកម្មមនុស្សខ្លះឲ្យទៅសោយទុក្ខនៅស្ថាននរកជាអនន្តកាលចំពោះបាបបន្តិចបន្តួចដូចនេះ? ។ ឡាក់គោលខាងគ្រិស្តសាសនាដែលពណ៌នានេះ ធ្វើឲ្យពួកពុទ្ធសាសនិកជនមានចិត្តជ្រួលជ្រើមជាខ្លាំង ។ ពួកពុទ្ធសាសនិកជនមិនអាចអនុម័តថា

ពួកក្រុមមនុស្សជាតិខ្លះសោយសម្បត្តិសុខជាអនន្តកាល ហើយមាន មនុស្សឯទៀតខ្លះសោយទុក្ខលំបាកជាអនន្តកាលដូចនេះ: ដរាបណាពួក លោកសន្និវាសនេះមានទុក្ខ, ដរាបណាសត្វទាំងអស់មិនទាន់រួចចាកទុក្ខ ទាំងពួង, ដរាបនោះគ្មានសន្តិភាពគ្មានសុខប្រាកដឡើយ ។

មានតែព្រះពុទ្ធមួយព្រះអង្គទេ ដែលទ្រង់ហ៊ានទតចំពីមុខបច្ចាមិត្ត ហើយទ្រង់ព្យាយាមដោះស្រាយនូវបញ្ហាបាបអកុសល ដែលទ្រង់បាន រកឃើញនូវមធ្យោបាយពិតប្រាកដ មានសភាពភ្លឺស្វាងជាអស្ចារ្យជា អនេក ។ ហេតុដែលកើតបាបនិងឧសថដែលអាចកំចាត់បង់បាបនោះ បាន សឹងមានពណ៌នាជាពិស្ដារក្នុងបឋមពុទ្ធវាចា ដែលព្រះអង្គបាន ទេសនានៅទីក្រុងប៉ាណារេះ (ពារាណសី) គឺជាគោលការណ៍សំខាន់នៃ ព្រះពុទ្ធសាសនា ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ទេសនាអំពីចតុរារិយ-សច្ចដែលជាមូលដ្ឋាននៃពុទ្ធវាចា ដូចនេះថា :—

"ម្នាលភិក្ខុទាំងឡាយ! ទុក្ខអរិយសច្ចនោះគឺ: ការកើតជាទុក្ខ, សេចក្តី គ្រាំគ្រាជាទុក្ខ, សេចក្តីឈឺចាប់ជាទុក្ខ, សេចក្តីស្លាប់ជាទុក្ខ, ការគប់ ប្រសព្វនូវអនិដ្ឋារម្មណ៍ជាទុក្ខ, ការព្រាត់ប្រាសចាកសត្វនិងសង្ខារដែល ជាទីស្រឡាញ់ពេញចិត្តជាទុក្ខ និងឧបាទានក្ខន្ធ ៥ ជាទុក្ខ[១] ។

(មានត)

---

១ ឧបាទានក្ខន្ធ ៥ គឺ: រូប (corps), វេទនា (sensations), សញ្ញា (idées), សង្ខារ (Volitions), វិញ្ញាណ (conseience) ។

# ពន្លឺអាស៊ីទ្វីប

## វគ្គទី ៦

La Lumière de l'Asie

## លោកស៊ើរ-អេតវីងអារណូលដ៍ តែង

*លោកប៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង*

(តមក)

---

ព្រះហត្ថាដាក់នៅលើព្រះជង្គង់; ព្រះនាង, អញ្ជើញមើល! មានរស្មីភ្លឺស្វាងរុងរឿងចេញពីព្រះនលាដ: ហើយព្រះអង្គមានព្រះបរិយាសូតគួរជាទីគោរពព្រមទាំងព្រះចក្ខុថ្លាបរិសុទ្ធស្អាតដូចមហាមេឃ! ព្រះនាងមានភ័ព្វសំណាងល្អបានមកជួបនឹងទេវតាដូចនេះ” ។

ព្រោះហេតុនេះ នាងសុជាតាយល់ថាជាទេវតាពិតប្រាកដ ក៏ថ្វាយបង្គំគោរពលើប្រថពី ហើយនាងឱនមុខ ពោលថា “សព្វបុគ្គលដែលនៅក្នុងគុម្ពោតព្រៃនេះឬ ដែលខ្ញុំបានបន់ស្រន់? ព្រះអង្គមានព្រះទ័យករុណាជាយ៉ាងក្រៃលែងចំពោះខ្ញុំព្រះអង្គដែលជាទាសី ដោយមានព្រះទ័យស្មោះសរនឹងខ្ញុំព្រះអង្គបញ្ចេញព្រះរូបឲ្យឃើញជាក់ច្បាស់, តើព្រះអង្គអាចទទួលនូវដង្វាយនេះ គឺមធុបាយាសដែលមានពណ៌សដូចព្រិលឬក្អកដែលជានរចនាដោយវិចិត្រឬ?” ។

លុះនាងពោលដូចនេះហើយ នាងក៏យកព្រះក្រយាហារនេះដាក់ក្នុងសុវណ្ណភាជន៍ ហើយស្រោចទៅលើព្រះហស្តព្រះពោធិសត្វនូវព្រះឧទកៈហៅថាអគ្គារ (altar) ដែលយកបណ្តូលបុប្ផាកុឡាបមកប្រកបហើយដាក់ក្នុងថូរកែវ ។ ព្រះបរមពោធិសត្វ សោយនូវមធុបាយាសនោះដោយស្ងៀមស្ងាត់ ។ ចំណែកនាងអង្គុយដោយគោរពក្នុងទីដ៏សមគួរ ។ ឱជារសនៃព្រះស្ងោយនោះប្លែកអស្ចារ្យ បានជាព្រះបរមពោធិសត្វសោយភ្លាមមានព្រះកាយពលដូចដើម បីដូចយប់ដែលព្រះអង្គទ្រង់ព្រះមិទ្ធៈ ឬថ្ងៃដែលទ្រង់អត់ព្រះក្រយាហារ ឬដូចជានិមិត្តយល់សប្តិ, ហើយព្រះប្រាជ្ញារបស់ព្រះអង្គ ក៏មានវិទ្ធានុភាពឡើងវិញ ព្រមទាំងព្រះកាយក៏មានកំឡាំងបរិបូណ៌ ដូចជាមានស្លាបហោះហើរភ្លាម ប្រៀបដូចបក្សាមួយ អស់កំឡាំងដោយហើរលើរលខ្សាច់ ហោស្ពានលន្ទមលន្ទោចជាប់កន្ទុយក្អែក ហើយមានចិត្តរីករាយសប្បាយដោយបានជួបទឹងស្ងឹងមួយ ហើយបានយកកន្ទឹងក្បាលដែលប្រឡាក់ដោយបរមាណូទៅជ្រមុជទឹក ។

នាងសុជាតាបានក្រាបសំពះព្រះបរមពោធិសត្វ ដោយបានឃើញព្រះភក្ត្រព្រះអង្គមានសភាពគួរឲ្យស្ញប់ស្ញែងពេក ហើយពោលពាក្យខ្សឹបៗ ថា: «ព្រះអង្គជាទេវតាឬ? ជន្សាយខ្ញុំព្រះអង្គ តើព្រះអង្គទ្រង់បានទទួលដោយព្រះទ័យស្មោះស្ម័គ្រឬ?» ។ ព្រះបរមពោធិសត្វមានព្រះបន្ទូលតបមកនាងវិញថា: «ភោជនាហារដែលនាងយកមកឲ្យយើងតើនាងធ្វើដោយអ្វី?» ។

នាងសុជាតាក្រាបទូលព្រះអង្គវិញថា: "ឱសត្តបុគ្គលដ៏ប្រសើរ! ខ្ញុំព្រះអង្គបានតែយកទឹកដោះគោញីចំនួន ១០០ ដែលទើបនឹងកើតកូន ហើយខ្ញុំព្រះអង្គយកទឹកដោះនោះទៅឲ្យគោញីមានពណ៌សចំនួនហាសិបបរិភោគ ហើយតែយកទឹកដោះគោញីទាំងប៉ុន្មាននោះទៅឲ្យគោញីម្ភៃប្រាំបរិភោគទៀត ទើបខ្ញុំព្រះអង្គតែយកទឹកដោះនេះទៅឲ្យគោញីដប់ពីរអា-ស្រ័យ ហើយតែយកទឹកដោះនេះទៅឲ្យគោញីប្រាំមួយដែលជាត់ធំល្អជាងគោញីឯទៀតក្នុងហ្វូងនោះបរិភោគ ទើបខ្ញុំព្រះអង្គតែយកទឹកដោះគោញីប្រាំមួយនេះមកដាក់ក្នុងភាជន៍ប្រាក់ អប់ដោយកំញាន លាយនឹងគ្រឿងទេសយ៉ាងបញ្ចង់ ហើយខ្ញុំព្រះអង្គបានយកអង្ករដែលបានមកពីយកពូជស្រូវ មកជ្រើសដោយហ្មត់ចត់យកទៅព្រោះនឹងដីដែលទើបភ្ជួររាស់ថ្មីៗ ហើយយកអង្ករទាំងនោះមកជ្រើសរើសថែមទៀត យកតែគ្រាប់ណាដែលធំក្តី នេះហើយក្រយាហារដែលខ្ញុំព្រះអង្គបានធ្វើដោយចិត្តស្មោះស្ម័គ្រ ព្រោះខ្ញុំព្រះអង្គបានប្តេជ្ញាក្នុងចិត្តថា នឹងយកតង្វាយទាំងនេះមកដាក់ក្រោមពោធិព្រឹក្សដើម្បីនឹងលាបំណន់របស់ខ្ញុំព្រះអង្គ ឥឡូវខ្ញុំព្រះអង្គបានបុត្រប្រុសមួយសម្រេចដូចបំណងហើយ ជីវិតខ្ញុំព្រះអង្គតាំងពីថ្ងៃនេះតទៅប្រកបដោយសេចក្តីសុខក្សេមក្សាន្តជាប្រាកដ" ។

ព្រះបរមពោធិសត្វ ទ្រង់បើកស្បៃក្រហមស្រស់ដែលរុំមុខនាង ហើយយកព្រះហស្តដែលស្រោចស្រង់សត្វលោកទាំងអស់ ដាក់លើ

ក្បាលនាងសុជាតា ហើយមានព្រះបន្ទូលថា: "សូមឲ្យនាងបានសេចក្តីសុខយូរអង្វែង, ហើយសូមឲ្យភារៈនៃជីវភាពរបស់តារកនោះឲ្យស្រាលល្មមនាងប្រព្រឹត្តទៅបានដោយស្រួល. ព្រោះនាងបានជួយជីវិតយើងៗមិនមែនជាទេវតាទេ តែទុកដូចជាមនុស្សមួយរបស់នាង; ពីដើមយើងជាព្រះអង្គម្ចាស់, ឥឡូវនេះយើងជាអ្នកដំណើរបំពេញទុក្ករកិរិយាអស់ប្រាំមួយឆ្នាំ ហើយស្វែងរកនូវរស្មីដែលភ្លឺចាំងអស់ទិវាកត្រៃនៅទីណាមួយ តែយើងមិនទាន់បានដឹងកន្លែងនោះនៅឡើយ, បើមនុស្សណារកឃើញ, មនុស្សនោះអាចដេញសភាពងងឹតល្ងង់ គឺអវិជ្ជានៃមនុស្សនោះចាកចេញពីសន្តានឲ្យមានពន្លឺភ្លឺស្វាងឡើងវិញបាន យើងមុខជានឹងឃើញនូវរស្មីនោះថ្ងៃណាមួយមិនខាន, រស្មីនោះយើងបានឃើញច្បាស់ដោយបញ្ញាចក្ខុរជាទីជ្រះថ្លាណាស់, កាលដែលយើងកំពុងខ្សោយ អន់ថយកំលាំងស្ទើរតែនឹងមរណា ទទួលបាននាងយកគោជនាហារដ៏វិចិត្រនេះដែលផ្សំពីកំលាំងសត្វជាច្រើនមកឲ្យយើង បានជាយើងមានពលភាពអស្ចារ្យដូច្នេះប្រៀបដូចជាជីវភាពត្រូវត្រាប់ផ្គត់ផ្គង់វត្តសង្សារជាច្រើនជាតិ. មុននឹងបានចំរើនឡើងតាមលំដាប់ទៅកាន់សុគតិ ហើយលះបង់នូវកម្មអកុសលបាន; តើនាងយល់ថាជីវភាពនេះឲ្យសុខឬ?" ។

នាងសុជាតាទូលតបទៅព្រះពោធិសត្វវិញថា: "ឱព្រះអង្គជាទីគោរព! ហទយវត្ថុខ្ញុំព្រះអង្គតូចណាស់ ប្រៀបដូចដំណក់ទឹកភ្លៀងបន្តិចបន្តួច

ដែលមិនអាចធ្វើឲ្យសើមដីក់លផង អាចដកពេញក្នុងស្រទាប់បុប្ផាលិស (lys) បាន ៗ ខ្ញុំព្រះអង្គស្រាប់តែឃើញព្រះសុរិយានៃជីវភាពក្ដីសប្បាយរីករាយនៅលើមុខស្វាមី ភាពញញឹម ចេញពីបបូរមាត់នៃបុត្រាដែលជាទីពេញចិត្ត, រក្សានូវសេចក្ដីស្នេហាអណ្ដែតត្រសែតក្នុងគេហដ្ឋាន; កាយរបស់ខ្ញុំព្រះអង្គហូរដូចទឹក, សុខស្រួលសប្បាយក្នុងការធ្វើអាហារព្រមទាំងថែទាំសំអាតផ្ទះសំបែង ក្នុងពេលបច្ចូសសម័យ, ខ្ញុំព្រះអង្គក្រោកឡើង សូត្រធម៌ថ្វាយបង្គំព្រះហើយបូជានូវគ្រាប់ឈើ បីបាច់ថែរក្សារុក្ខជាតិហៅថា ទុលស៊ី (toulsi) ហើយចែកកិច្ចការដែលត្រូវធ្វើឲ្យទៅពួកទាសី, ក្នុងពេលអធិទិវា (au milieu du jour) ក្បាលស្វាមីខ្ញុំព្រះអង្គកើយលើភ្លៅខ្ញុំព្រះអង្គហើយនិទ្រាលក់ និមិត្តសប្បាយក្នុងមនោទ្វារ, មានទាសីបក់ផ្លិតឲ្យហើយត្រជាក់ស្រួល, លុះដល់ពេលបាយល្ងាចក្នុងសាយណ្ហសម័យ ខ្ញុំព្រះអង្គទៅអង្គុយជិតស្វាមី យកនំជូនលោកពិសារ, របបាទជូនតាកបញ្ចេញរស្មីមានពណ៌សដូចជាប្រាក់ ជាសំពៀនខ្ញុំព្រះអង្គឲ្យចូលដំណេក ក្រោយដែលបានទៅសូត្រធម៌នៅព្រះវិហារនឹងសន្ទនាការតាមគំសាន្តចំពោះញាតិមិត្ត ៗ បើយ៉ាងដូចនេះ ម្ដេចក៏ខ្ញុំព្រះអង្គមិនសប្បាយរីករាយ ចិត្តដែលប្រាថ្នាទាំងអម្បាលម៉ានសម្រេចដូចបំណងហើយ ថែមទាំងមានបុត្រប្រុសមួយដែលមានដៃតូចសម្រាប់បិទភ្នែកស្វាមីខ្ញុំព្រះអង្គនាំវិញ្ញាណក្ខន្ធទៅកាន់ស្ថានសួគ៌ ដល់ពេលមច្ចុរាជមក

ផល. ព្រោះគម្ពីរសាស្ត្រថ្លែងថា: "បើមានមនុស្សម្នាក់ដាំដើមឈើមួយដើមដើម្បីឲ្យម្លប់ដល់អ្នកដំណើរដែក ឬបានជីកអណ្តូងមួយជាសាធារណៈប្រយោជន៍ដល់ប្រជាជនហើយមានបុត្រប្រុស មនុស្សនោះលុះធ្វើកាលកិរិយាទៅកាន់បរលោក បាននូវសុគតិភពមិនខាន" ។ ខ្ញុំព្រះអង្គមានសទ្ធាជឿជាក់នូវគម្ពីរទាំងនោះ ដោយខ្ញុំព្រះអង្គមិនមានគុណសម្បត្តិស្មើនឹងពួកសន្តបុគ្គលពីបុរាណកាល ដែលលោកអាចចរចាជាមួយពួកទេវតា ហើយលោកចេះសូត្រធម៌ចេះធ្វើឲ្យគេពេញចិត្ត ស្គាល់ផ្លូវនៃគុណធម៌គ្រប់យ៉ាងព្រមទាំងសន្តិសុខ ។ ខ្ញុំព្រះអង្គយល់ឃើញថា កុសលកើតមកពីចិត្តល្អ, អកុសលកើតមកពីចិត្តលាមកចំពោះវត្ថុទាំងអស់ក្នុងលោកមិនថានៅទីកន្លែងណា ក្នុងពេលណា គ្មានកំណត់ឡើយ; ព្រោះខ្ញុំព្រះអង្គបានឃើញថា ផលដែលមានរសជាតិសង្វាញ់ពិសារដុះនៅលើរុក្ខា ដែលមានសុខភាពដ៏បរិបូណ៌, ឯផ្លែដែលមានជាតិល្វីងដុះនៅលើរុក្ខាដែលមានរសជាតិពុល; ខ្ញុំព្រះអង្គឃើញថាក្នុងជីវភាពនេះ ចិត្តកាចនាំឲ្យទៅកាន់សេចក្តីស្អប់ខ្ពើម, ចិត្តល្អនាំទៅកាន់កល្យាណមិត្តភាព, ចិត្តខន្តីនាំទៅកាន់សន្តិសុខ; បើកាលណាចុតិចិត្តចូលកាន់មរណសញ្ញាហើយតើយើងនឹងបានសេចក្តីសុខតទៅអនាគតជាងសុខក្នុងបច្ចុប្បន្ននេះឬ? ប្រហែលជាបានសេចក្តីសុខជាងនោះទៅទៀត; ព្រោះថា ស្រូវមួយគ្រាប់បានឲ្យកើតជាធញ្ញជាតិមួយដើមមានពណ៌ខៀវស្រងាត់ ហើយចំរើនបានផ្លែហាសិប

គ្រាប់រលោងភ្លឺដូចខ្លួនមុក្តា ហើយបុប្ផាដែលមានទ្រង់ទ្រាយដូចតារារបស់ព្រឹក្សជាតិចំបក់ (Champaks) មានសម្បុរមាសជ្រុះធ្លាក់ទៅក្នុងគុម្ពោតព្រៃដែលមានពណ៌ប្រផេះឯណោះ ៗ ឱព្រះអង្គ ! ខ្ញុំព្រះអង្គដឹងថាគេអាចស៊ូទ្រាំនូវទុក្ខលំបាក ៗ ដែលអាចផ្តួលធម៌ខន្តីបានទៅលើធូលីដីដែលនៅតាមផ្លូវធ្លា ៗ បើកូនប្រុសខ្ញុំព្រះអង្គទទួលអនិច្ចកម្មមុនខ្ញុំព្រះអង្គ ៗ គិតថាហទយវត្ថុខ្ញុំព្រះអង្គនឹងបែកប្រេះធ្លាយ ហើយខ្ញុំព្រះអង្គពេញចិត្តទុកជាមុនថាហទយវត្ថុនោះនឹងប្រេះធ្លាយដូចបំណងចុះ ឲ្យតែខ្ញុំព្រះអង្គបានឱបបីបមថ្នមកូនប្រុសដែលក្ស័យជន្មាទៅ, ហើយខ្ញុំព្រះអង្គមុខជានឹងបានទៅកាន់សុគតិភព គឺភពដែលជាផលសម្រាប់កិរិយាដែលមានចិត្តត្រង់នឹងស្វាមី រីឯចាំស្វាមីខ្ញុំព្រះអង្គលុះត្រាតែលោកទទួលមរណភាពជាបរិយោសាន ៗ តែបើស្វាមីខ្ញុំព្រះអង្គទទួលអនិច្ចកម្មនៅក្ងូមិសេនាទិមុនខ្ញុំព្រះអង្គ ៗ សូមបួលទៅស្ថិតនៅក្នុងដើងថ្ក ហើយខ្ញុំព្រះអង្គជាក់ក្បាលស្វាមីលើភ្លៅ ដូចខ្ញុំព្រះអង្គធ្លាប់ធ្វើសព្វថ្ងៃ, ហើយខ្ញុំព្រះអង្គសំដែងទឹកចិត្តប្រកបដោយបីតិជាខ្លាំង បើកាលណាខ្ញុំព្រះអង្គបានឃើញអណ្តាតភ្លើងឆាបឆេះរលាយទៅជាផេះជាមួយស្វាមី ព្រោះមានចារឹកទុកក្នុងគម្ពីរថា បើស្ត្រីជាតិឥណ្ឌៀស៊ូធ្វើពលិកម្មនូវជីវិតបែបនេះ សេចក្តីស្នេហានោះឲ្យផលដ៏ល្អដល់អាត្មននៃស្វាមី អាចទៅសោយសម្បត្តិនៅស្ថានសួគ៌ទេវ-លោកចំនួនមួយកោដិឆ្នាំ គិតក្នុងសក់មួយសរសៃៗ ៗ ព្រោះហេតុដូចនេះ

បានជាខ្ញុំព្រះអង្គគ្មានភ័យខ្លាចអ្វីឡើយ ហើយជីវភាពខ្ញុំព្រះអង្គ ក៏ប្រព្រឹត្តជាសុខសប្បាយតរៀងមក, ពិតមែនតែខ្ញុំព្រះអង្គមិនបានក្ដោបនូវជីវិតឯទៀតជាច្រើន ដែលកើតមករងទុក្ខលំបាកគ្រប់យ៉ាង គឺក្រ ទុព្វលភាព, ហើយទុរគតអត់ឃ្លាន ដែលទេវតាឥន្ទ្រព្រហ្ម ឬអសេក្ខបុគ្គលមានព្រះទ័យករុណាពន់ពេកនោះឡើយ ; តែចំណែកខ្ញុំព្រះអង្គខំស្វែងរកបំពេញករណីយកិច្ច តាមជនសាមញ្ញដែលខ្ញុំព្រះអង្គយល់ថាជាកិច្ចប្រសើរ ហើយខ្ញុំព្រះអង្គរស់នៅប្រតិបត្តិតាមច្បាប់ ដោយសង្ឃឹមទុកជាមុនថាកម្មផលដែលខ្ញុំព្រះអង្គទទួល ឬមានមកក្នុងកាលជាអនាគតជាសោភណផល" ។

ព្រះបរមពោធិសត្វ ទ្រង់មានព្រះបន្ទូលតបទៅនាងសុជាតាវិញថា: "នាងបេះទូងបានប្រដៅពួកគ្រូអាចារ្យ ។ ប្រាជ្ញានាងពិតមែនតែសាមញ្ញ តែគួរឲ្យសរសើរ ព្រោះមានសភាពវិសេសថ្លៃថ្លាលើសវិជ្ជាទាំងពួង ។ ចូរនាងនៅជាសុខចុះ ដោយនាងដឹងច្បាស់ថាខ្លួននាងល្ងង់ព្រោះនាងបានស្គាល់ផ្លូវនៃយុត្តិធម៌ នឹងករណីយកិច្ចរបស់នាង ; ចូរនាងនៅដូចបុប្ផាជុះ ហើយឲ្យម្លប់ទៅបុត្រប្រុសជ្រកតាមប្រាថ្នា ; រស្មីនៃសច្ចធម៌ក្ដៅខ្លាំងពេក មិនមែនបញ្ចាំងសម្រាប់ស្លឹកព្រឹក្សាជាតិមានសភាពទន់ទោរ ដែលនឹងអាចចំរើននូវជីវភាពបាននៅក្រោមព្រះសុរិយាដទៃនោះឡើយ ឬដែលនឹងបញ្ចេញនូវជីវភាពប្រកបដោយហាសិតុប្បាទ ប្រៀបដូចជាបុប្ផាក្រអូបឈ្ងុយឈ្ងប់ងើយស្រពាប់ទៅពន់មហាមេឃដូចនោះ ។ (មានត)

# ធម្មបរិយាយកថា

ព្រះគ្រូបញ្ញាលិខិត កៅ-សឹម សាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់

ទេសនាដាក់វិទ្យុឃោសនសព្ទនៃប្រទេសកម្ពុជា កាលពីថ្ងៃទី ២២ ខែកញ្ញា គ. ស. ១៩៤៧

---

## នមត្ថុ រតនត្តយស្ស

លំដាប់តទៅនេះ, សូមសំដែងធម្មទេសនា ជាធម្មបរិយាយផ្សាយតាមវិទ្យុ ដោយសេចក្ដីសង្ខេប ដើម្បីនឹងញុំាងទឹកចិត្តនៃសាធុជន ជាសប្បុរស អ្នកដែលមានសទ្ធានឹងសេចក្ដីជ្រះថ្លាក្នុងបវរពុទ្ធសាសនា ឲ្យចុះស៊ប់កាន់ធម៌ទេសនាតាមនិពន្ធគាថា ដូចតទៅនេះ :—

យថាបិ នាម ជច្ចន្ធោ នរោ អបរិណាយកោ
ឯកទា យាតិ មគ្គេន កុម្មគ្គេនាបិ ឯកទា
សំសារេ សំសរំ ពាលោ តថា អបរិណាយកោ
ករោតិ ឯកទា បុញ្ញំ អបុញ្ញម្បិ ឯកទា
យទា ច ញត្វា សោ ធម្មំ សច្ចានិ អភិសមេស្សតិ
តទា អវិជ្ជូបសមា ឧបសន្តោ ចរិស្សតិ ។

ប្រែថា : "មនុស្សខ្វាក់អំពីកំណើត (តាំងពីលើផែនដី) បើមិនមានគេដឹកដៃនាំមុខទេ ជួនដើរត្រូវផ្លូវ ជួនដើរខុសផ្លូវ យ៉ាងណាមិញ ;

មនុស្សពាលគោគល្ងង់ខ្លៅ កាលចរត្រាច់ស្ទាត់ទៅក្នុងវាលវដ្ដសង្សារ បើមិនមានបណ្ឌិតដឹកនាំមុខទេ ជួនធ្វើបុណ្យ ជួនធ្វើបាប ក៏យ៉ាងនោះដែរ; លុះតែមនុស្សពាលនោះ យល់ធម៌ច្បាស់លាស់ ត្រាស់ដឹងនូវអរិយសច្ច ៤ ប្រការពេលណា នឹងជាបុគ្គលប្រព្រឹត្តសន្តិសុខស្ងប់ស្ងាត់ពេលនោះ ព្រោះបានរម្ងាប់នូវអវិជ្ជា " ។

គតិនេះ នឹងអធិប្បាយព្រះពុទ្ធភាសិតខាងលើនេះតទៅ :—

ព្រះសម្ពុទ្ធវិសុទ្ធិគុណទ្រង់ជ្រាបច្បាស់ថា ពួកសត្វនិករទាំងឡាយដែលលិចលង់ក្នុងអំណាចអវិជ្ជាត្រេកអរក្នុងសង្សារវដ្ដ តែងមានគំនិតត្រិះរិះពិចារណាយល់ឆ្គង តាក់តែងគ្រឿងផ្សំជាបុណ្យក៏មាន ជាបាបក៏មាន មិនប្រាកដ ដូចមនុស្សខ្វាក់ដើរព្រាវលើផែនដី ជួនចំផ្លូវ ជួនខុសផ្លូវ ពានទៅលើទីទួល ទីទាប មិនរាបមិនស្មើ ជាហេតុឲ្យបានសេចក្ដីទុក្ខលំបាកច្រើន ៗ ឯសព្វសត្វក្នុងលោកសន្និវាសនេះ សុទ្ធសឹងតែប្រាថ្នារកសេចក្ដីសុខចំរើនគ្រប់ៗគ្នា តែជួនពារពានទៅលើទុក្ខក៏មានជួនពារពានទៅលើសុខក៏មាន ដោយហេតុមកពីគំនិតយល់ត្រូវ នឹងយល់ខុស, កាលបើគិតត្រូវ យល់ត្រូវ ប្រកបកិច្ចការងារត្រូវ ក៏បានសេចក្ដីសុខចំរើន, បើគិតខុស យល់ខុស ប្រកបកិច្ចការងារខុស ក៏បានសេចក្ដីទុក្ខមិនបានចំរើន ព្រោះមកពីមានប្រាជ្ញា នឹងខ្វះប្រាជ្ញាជាបុព្វហេតុ ។

គំនិតមនុស្សដែលយល់ឆ្គង មិនត្រូវតាមហេតុ ស្មានហើយផ្សំយកគ្មានទីពឹងបំណេះវិជ្ជាអ្វីយកមកពិចារណាពិនិត្យពិច័យឲ្យច្បាស់លាស់ថា

មុនសិន ស្រាប់តែប្រកបកិច្ចការងារនោះ ធ្វើទៅតាំងស្ពាន រាប់អាន គោរពបូជាទៅតាំងបំពាន ក្នុងពេលដែលខ្លួនបានសេចក្ដីទុក្ខលំបាក មាន ខ្លះទៅបន់ស្រន់នៅទីកន្លែងណាមួយ មានដើមឈើជាដើម ដោយយល់ ខុសថា : ដើមឈើនោះៗឲ្យសិរីសួស្ដីមង្គលដល់ខ្លួន នឹងគ្រួសាររបស់ ខ្លួន ៗ មិនតែប៉ុណ្ណោះថែមតាំងធ្វើទេវដ្ឋានអាស្រមខ្មួម-ពេងសាងទេវរូប ជារូបអ្នកតាឃ្លាំងមឿងប្រចាំស្រុក រូបដុំថ្មដាក់ដំកល់ក្នុងទេវដ្ឋាននោះៗ សម្រាប់ទុកគោរពរាប់អានបូជាគោតខ្វាច គ្រប់ស្រុកគ្រប់ភូមិរាល់ឆ្នាំ ពួក អ្នកស្រុកតាំងប្រុសស្រីចាស់-ក្មេងប្រជុំគ្នាទៅបូជាយិដ ហៅថាឡើង អ្នកតា មានចាប់សត្វក្របី-ស្វា-មាន់-ទា នឹងជ្រូកជាដើម តាមចំណូល អ្នកតាយកទៅបូជា ដោយធ្វើពិធីសម្ដាប់ពន្ទាត់ស្បែកដោតត្រាងត្រដាង ថ្វាយនៅមុខអ្នកតា ដឹកស្រា-ស៊ុសាច់-សែនពៃជ្រូបស្រា-អុជធារហោ៊ កញ្ច្រៀវ-លេងភ្លេង-បញ្ជាន់រូបអារក្ស សូមសិរីសួស្ដីតបះតេជះអំពី អ្នកតាថា : សូមធ្វើស្រែស្រូវអង្ករ-ល្ង-សណ្ដែក-ដាំពេក-អំពៅក្នុងឆ្នាំ នេះឲ្យបានផលផ្លែបរិបូណ៌, សូមឲ្យទឹកភ្លៀងធ្លាក់ចុះមកបរិបូណ៌, សូមឲ្យ សប្បាយដល់គ្រួសារគ្រប់ៗគ្នាកុំឲ្យវេទនា ដូច្នេះក៏មាន ៗ ចួនកាលប្រើ គំនិតព្រាវទៅលើទីវត្តអារាម ដែលជាទីគួរជ្រះថ្លាគោរពបូជារបស់អ្នកកាន់ ព្រះពុទ្ធសាសនា ថាជាទីនៅអាស្រ័យនៃខ្មោចល្បាក់សា បិសាចចំបូរដូរ ប្ដូយាយទេព្យ ដែលធ្វើខ្លួននឹងគ្រួសារឲ្យបានទុក្ខលំបាក ហើយក៏លន់តួ

ទោសបៃរបន់បួងសួងសូមសេចក្ដីសុខសប្បាយដល់ខ្លួននឹងគ្រួសារ សូមលើកគ្រឿងថ្វាយបូជាបាយសីស្លាធ័រ - ស្លាធម - បូជាបេក - ថ្វាយស្រា - ថ្វាយមាន់ - ថ្វាយទា កោរក្បាលថ្វាយ ទើងបួស ១ សំកាំងជ័រថ្វាយដូច្នេះក៏មានៗ

ហេតុនេះយើងជាតិមនុស្សប៉ុប៉ុជួន ក្នុងពេលដែលបានទុក្ខលំបាក ហើយ កុំអាលប្រញាប់ដាក់ទោសទៅលើខ្មោចល្បាក់សាច់បួរផ្លូរនោះពេក គួរគិតពិចារណារករកឲ្យឃើញហេតុផលសិនសឹមធ្វើទើបល្អ ៗ ឯចៃដ្រ អពមង្គលទល់ទុក្ខលំបាកនោះ មិនមែនដើមឈើដុំថ្មឲ្យទេ គាមពិត នោះគឺអវិជ្ជាធ្វើឲ្យបានទុក្ខវេទនា ៗ

មនុស្សអ្នកជឿហេតុខាងក្រៅ បដិសេធផលកម្មរបស់ខ្លួនពោល ទឹងឲ្យឈ្មោះថាជាមនុស្សគិតត្រូវ យល់ត្រូវ ធ្វើការងារត្រូវឯណាកើត? ធ្វើម្ដេចនឹងបានសេចក្ដីសុខចំរើន? ព្រោះជាអ្នកកាន់ប្រទាំ្យ លុះក្នុងអំណាច អវិជ្ជាគ្របសង្កត់ជាប់ ច្រើនចូលចិត្តផ្សំថា: បើមនុស្សយើងបរិភោគវត្ថុយ៉ាងណា ខ្មោចឬទេវតា ភ្លើង ក៏គង់ចូលចិត្តបរិភោគវត្ថុយ៉ាងនោះដែរ; ក្លួយ៉ាងគេនាំគ្នាពប់អានធ្វើពិធីបូជាភ្លើង គឺគេនាំគ្នាជីករណ្ដៅនៅទីកន្លែងណាមួយ ហើយយកភ្លើងទៅបង្កាត់ក្នុងរណ្ដៅនោះឲ្យឆេះសន្ធៅឡើង ទើបយកសត្វតិរច្ឆាន ឬមនុស្សទៅសម្លាប់សំឡេះយកសាច់ទំលាក់បង់ទៅក្នុងគំនរភ្លើងឲ្យភ្លើងបរិភោគសាច់នោះ ដើម្បីសូមសុខសួស្ដីឲ្យកើតឡើង ដោយកម្មសិទ្ធនេះ ៗ

ព្រះសម្ពុទ្ធទ្រង់បានជ្រាបច្បាស់ថាពួកសត្វ នាំគ្នាធ្វើពលិកម្មបូជាកប់ កាន់ខ្ជូវទេវរូបនឹងការបូជាភ្លើងយ៉ាងនេះ ដោយដើរផ្លូវខុសទំនងមិនសមហេតុផលទេ ទើបទ្រង់ប្រែនយោបាយផ្លាស់ផ្លូវកម្មសិទ្ធរបស់សត្វទាំងនោះ ទ្រង់ដឹកនាំផ្លូវជាធម្មសិទ្ធដោយសំដែងប្រាប់ពលិកម្ម ៥ យ៉ាង ជាគ្រឿងបំភ្លឺឲ្យផ្លាស់គំនិតល្ងង់យល់ខុសនោះ ទៅជាគំនិតត្រូវវិញ ។

ឯពលិកម្ម ៥ នោះដូចតទៅនេះ :

១ — **ញាតិពលិ** = សង្គ្រោះញាតិសន្តានដែលរស់នៅ,

២ — **អតិថិពលិ** = ទទួលភ្ញៀវដែលមកដល់ទីលំនៅខ្លួន,

៣ — **បុព្វប្បេតពលិ** = ធ្វើបុណ្យឧទ្ទិសផលបញ្ជូនទៅបុព្វបុរស, មានមាតាបិតាជាដើម ដែលចែកឋានទៅហើយ,

៤ — **រាជពលិ** = បង់ពន្ធដារជូនរាជការផែនដី,

៥ — **ទេវតាពលិ** = ធ្វើបុណ្យឧទ្ទិសផលដល់ពួកទេវតា ។

ពលិកម្ម ៥ នេះហើយ ជាផ្លូវនាំឲ្យបានសេចក្តីសុខចំរើនទាំងលោកនេះនឹងលោកខាងមុខ ជាដំណើរចៀសវាងអំពីផ្លូវគោគល្ងង់ខ្លៅកាន់ច្រឡំរបស់មនុស្សដែលឥតគំនិតឥតប្រាជ្ញាមិនបានការនោះ ។ ។

គំនិតដែលកាន់ច្រឡំយ៉ាងនេះមុខជានឹងច្រឡំដោយពៀរត្រឡប់សាមកលើខ្លួនអ្នកធ្វើវិញមិនខាន សមដូចព្រះសម្ពុទ្ធទ្រង់ពោលទុកមកថា :

បរទុក្ខូបធានេន យោ អត្តនោ សុខមិច្ឆតិ
វេរសំសគ្គសំសដ្ឋោ វេរា សោ ន បរិមុច្ចតិ ។

" អ្នកណាប្រាថ្នាសុខចំពោះខ្លួន ដោយការបំពេញទុក្ខទៅលើអ្នកដទៃ អ្នកនោះឈ្មោះថាជាប់ចំពាក់ផ្ទាក់ដោយពៀរ រមែងដោះខ្លួនមិនរួចផុតស្រឡះចាកពៀរឡើយ " ។

ការទំលាក់ទុក្ខទោសទៅលើអ្នកឯទៀតនោះ គួរជ្រាបថា : តែងឲ្យផលសងសឹកមកខ្លួនវិញ ត្រូវតាមដំណើរដើមដែលខ្លួនធ្វើទៅលើគេ ឬក៏ឲ្យផលខុសពីស្ថានដើម តែត្រូវគេពិន័យជាបទអាជ្ញា ត្រូវជាប់គុកច្រវាក់ ឬក៏ក្លាយឲ្យផលត្រូវទទួលរងគ្រោះថ្នាក់ ១០ យ៉ាងផ្ទួនបណ្ដាលឡើង គឺ: ១ – ត្រូវរងទុក្ខវេទនាយ៉ាងខ្លាំង; ២ – ត្រូវវិនាសសាបសូន្យចាកយសស័ក្តិ; ៣ – ត្រូវបែកធ្លាយសរីរៈរាងកាយ; ៤ – ត្រូវមានជម្ងឺឈឺជាទម្ងន់; ៥ – ត្រូវបានសេចក្តីក្រឡកចិត្តឆ្កួត; ៦ – ត្រូវស្តេចរឹបជាន់; ៧ – ត្រូវគេពោលបង្កាច់យ៉ាងអាក្រក់; ៨ – ត្រូវទិពសព្រាត់ប្រាសចាកពួកញាតិសន្តាន; ៩ – ត្រូវហិនហោចខូចខាតទ្រព្យសម្បត្តិ; ១០ – ត្រូវភ្លើងឆេះផ្ទះ (អន្ទះបាញ់បំផ្លាញអ្នកនោះ) លុះបែកធ្លាយរាងកាយទៅ អ្នកដែលមានគំនិតយល់ខ្លួនឥតប្រាជ្ញា អវិជ្ជាគាត់តែងគ្រឿងផ្សំសង្ខារឲ្យទៅកើតក្នុងកន្លែងនរក ។ នេះហើយជាផលក្លាយខុសចាកស្ថានដើម ជាផលដែលដេញទាន់ជាន់កែងដូចសំដែងមកនេះ ។

ធម្មតាមនុស្សឆោតល្ងង់ប្រកាន់ទិដ្ឋិ ទំលាក់ក្រាញគំនិតអាក្រក់ គំនិតព្យាបាទខឹងប្រទូស្តអ្នកដទៃ តែងមិនរួចផុតអំពីបំណង ៧ យ៉ាងជាគ្រឿងចងភ្ជួងរបស់អវិជ្ជា ឲ្យជាប់កើតស្លាប់ត្រៀបត្រាក្នុងវដ្តសង្សារនេះគឺ

១ – **រាគពន្ធន**: អវិជ្ជាចងភ្ជួងដោយកាមគុណ ៥ គឺឲ្យសម្បូណ៌ដោយរូប- សំឡេង- ក្លិន- រស- សម្ផស្ស ;

២ – **ទោសពន្ធន**: អវិជ្ជាចងភ្ជួងដោយបដិឃៈ គឺឲ្យសម្បូណ៌ដោយទោសៈ សេចក្តីក្រោធពិរោធខឹងវាយដំប្រចំដាក់ កាប់សម្លាប់គ្នា បៀតបៀនគ្នា ព្យាបាទគ្នាទាល់តែវិនាសរៀងខ្លួន ;

៣ – **មោហពន្ធន**: អវិជ្ជាចងភ្ជួងដោយមោហៈ គឺឲ្យសម្បូណ៌ដោយសេចក្តីវង្វេង កាន់ប្រឡំ ឆោតល្ងង់ខ្លៅ ;

៤ – **ទិដ្ឋិពន្ធន**: អវិជ្ជាចងភ្ជួងដោយទិដ្ឋិ គឺឲ្យសម្បូណ៌តែខាងឃើញខុស យល់ខុសប្រកាន់ខុសថាជាត្រូវៗ ថាជាខុសដោយផ្លូវសស្សតទិដ្ឋិ គឺយល់ឃើញទៀងថា: សត្វលោកដែលធ្លាប់កើតយ៉ាងណា ស្លាប់ទៅវិញក៏ទៅកើតជាយ៉ាងនោះដដែលមិនប្រែប្រួល, ឧច្ឆេទទិដ្ឋិ យល់ឃើញថា : សត្វលោកស្លាប់ហើយសូន្យ មិនមានអ្វីនាំឲ្យទៅកើតទៀតទេ ;

**៥ – មានពន្ធនៈ** អវិជ្ជាចងផ្ចឹងដោយមានៈ គឺឲ្យសម្បូណ៌ដោយរឹងត្អឹងលើកខ្លួនឲ្យខ្ពស់ប្រសើរជាងគេ មិនព្រមជឿស្តាប់បង្គាប់អ្នកណា ចចេសយកឈ្នះតែម្នាក់ឯង ;

៦– កិលេសពន្ធនៈ អវិជ្ជាចងផ្ចឹងដោយកិលេសជាគ្រឿងរឹតរុំ គឺឲ្យសម្បូណ៌ដោយសំយោជនកិលេសទាំង ១០ ដែលធ្វើចិត្តសត្វឲ្យសៅហ្មង វិលស្លាប់វិលកើតក្នុងវដ្តទុក្ខ ;

៧– ទុច្ចរិតពន្ធនៈ អវិជ្ជាចងផ្ចឹងដោយទុច្ចរិតទាំង ៣ គឺឲ្យសម្បូណ៌ដោយសេចក្តីប្រព្រឹត្តិអាក្រក់ ដោយកាយ-វាចា-ចិត្ត ។

កាលមនុស្សពាល ដែលអវិជ្ជាចងផ្ចឹងដោយចំណងទាំង ៧ នេះ តែងបានសេចក្តីវិនាស សេចក្តីទុក្ខ ហេតុនោះ សាធុជនអ្នកដែលប្រាថ្នាសេចក្តីសុខចំរើន គួរខ្វាចបៀសវាងឲ្យផុតកុំឲ្យជួបប្រទះនឹងចំណងទន្ទឹងនេះ ៗ សំដែងមកក្នុងធម្មបរិយាយកថាដោយសេចក្តីសង្ខេបតែប៉ុណ្ណោះ ។

ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា
សោកប្បត្តា ច និស្សោកា សុខី ហោន្តុ សាធវោ ។

សូមសាធុជនអ្នកស្តាប់ធម៌ទាំងឡាយ (ដែលផ្សាយតាមវិទ្យុនេះ) ជនណាដែលដល់ហើយនូវទុក្ខ សូមកុំឲ្យមានទុក្ខ, ជនណាដែលដល់ហើយនូវសេចក្តីភ័យ សូមកុំឲ្យមានភ័យ, ជនណាដែលដល់ហើយនូវសេចក្តីសោក សូមកុំឲ្យមានសោក, សូមឲ្យបានសម្រេចនូវសេចក្តីស្អាតបរិសុទ្ធគ្រប់ៗគ្នាឡើង ។

ការបណ្ដុះនិស្ស័យ

# ព្រះមហាឧត្តមវិជ្ជា ផលញ្ញាណោ ប៊ុង-ប៉ម

អាចារ្យសាលាបាលីរង វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

## ឃុនបណ្ឌានុរក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យកែ

(តមក)

តែនិស្ស័យរបស់មនុស្សយើង សូម្បីបែបណាក៏ដោយ ក៏គង់ជាវត្ថុដែលនឹងអាចកែខៃឬបណ្ដុះឡើងបាន ហើយនឹងប្ដូរថ្មី ស្រួងកែថ្មី ចំពោះត្រង់ឋានៈដែលខ្លួនមិនធ្លាប់មានមកពីដើមបានទាំងអស់, ដូចជានិស្ស័យអាក្រក់ក៏គង់តែកែប្រែឲ្យត្រឡប់ទៅជាល្អបាន ។ ចូរមើលមនុស្សទាល់ក្រ ឬមនុស្សថោកទាប តាំងខ្លួនឲ្យជាមនុស្សមាំទាំ ឬលើកឋានៈរបស់ខ្លួនឲ្យខ្ពស់ឡើង ដែលយើងឃើញគ្រានេះជាព័ស្ដុគាង ដូចជាដធ្ខៅ ថៅកែ គហបតី ឬអ្នកមានសិល្បវិជ្ជា មានយសសក្ដា មានតំណែងនាទី តាំងអំពីទាបរហូតដល់ខ្ពស់ សុទ្ធតែបានបណ្ដុះខ្លួនឲ្យមាននិស្ស័យល្អទាំងអស់ មិនមែនជាមិនធ្វើសេចក្ដីល្អអ្វីមួយ ហើយស្រាប់តែក្លាយទៅជាមនុស្សល្អឡើយ ។

ពិតមែន ! ជីវិតរបស់មនុស្សយើងនេះ រមែងជាបច្ច័យដើម្បីទ្រទ្រង់គុណ សេចក្ដីល្អ ទ្រព្យសម្បត្តិ សុខសម្រាន្តនឹងសេចក្ដីបរិសុទ្ធ ដរាបដល់ផុតចាកកិលេសបាបធម៌ទាំងពួង ។ កាលបើជីវិតគ្មានសារៈហើយ

វត្ថុទាំងអស់ក៏គ្មានសារៈដែរ, កាលបើជីវិតមានសារៈហើយ វត្ថុទាំងអស់ក៏ត្រូវតែមានសារៈដែរ តែជីវិតរបស់យើងនឹងបានជាបច្ច័យដើម្បីជាទីតាំងនៅនៃគុណវត្ថុដែលជាសារៈទាំងឡាយ រមែងមានប្រាកដឡើងក្នុងការងារដែលយើងធ្វើខ្លួនឯង ដោយបានអប់រំខ្លួនទុកមកពីមុនជាហេតុ ។ សូម្បីការអប់រំខ្លួននោះ ក៏មិនមែនដទៃឆ្ងាយ គឺការបណ្ដុះនិស្ស័យនេះឯង បើយើងប្រាថ្នាប្រយោជន៍ជាសំខាន់ យើងត្រូវតែខំបណ្ដុះនិស្ស័យ ព្រោះយើងនឹងទៅជាមនុស្សល្អបាន ដោយសារតែការបណ្ដុះនិស្ស័យឲ្យល្អ សូម្បីនឹងទៅជាមនុស្សអាក្រក់ ក៏ដោយសារតែការអប់រំខ្លួនឲ្យប្រឡូកប្រឡំទៅក្នុងផ្លូវអាក្រក់ ។ មនុស្សមាននិស្ស័យអាក្រក់ បែរមុខទៅរកតែទីទាប ព្រោះត្រូវអំណាចខាងទាបប្រទាញឲ្យធ្លាក់ចុះទៅកាន់ថ្នាក់ទាប មិនមានឱកាសដែលនឹងព្យាយាមធ្វើចិត្តឲ្យឡើងទៅកាន់ថ្នាក់ខ្ពស់បានទេ មានជីវិតដូចជាទូកដើរក្នុងទន្លេឬសមុទ្រ ដែលឥតចង្កូតនឹងត្រីវិស័យ មិនមានអ្វីជាគ្រឿងជម្រង់សោះ, គឺជាមនុស្សដែលគ្មានច្បាប់ជាគ្រឿងបង្គាប់ ។ បើឥតច្បាប់ ក៏ឥតរបៀប, បើឥតរបៀបហើយ ក៏ឥតមានសេចក្ដីល្អសោះឡើយ ។

ចំណែកមនុស្សដែលមាននិស្ស័យល្អ រមែងមានលក្ខណៈល្អៗ ដែលរកបានក្រនៅក្នុងខ្លួនច្រើនយ៉ាង ជាកំពូលនៃសេចក្ដីល្អ ជាសិរីសម្រាប់រូបមនុស្ស ។ តាមពិត ការមាននិស្ស័យល្អ ត្រឹមតែមួយក្ដាប់ប៉ុណ្ណោះ

គន់ល្អលើសជាងការដែលមានសេចក្ដីចេះដឹងល្អច្រើនទាំងកញ្ចើ ព្រោះហេតុអ្វី? ព្រោះហេតុថា មនុស្សដែលមានចំណេះល្អនោះ សូម្បីជាអ្នកឈ្លាសវាងវៃ រៀនអ្វីបានចេះឆាប់ក្លាមៗ ក៏ដោយ តែបើនិស្ស័យអាក្រក់ហើយ ក៏នឹងកើតសេចក្ដីចេះដឹងហួសប្រមាណ ក្លាយទៅជាមនុស្សឃោងអួតខ្លួន លើកខ្លួនឯង មើលងាយអ្នកដទៃដែលអន់ជាងខ្លួនកង់រឿងបញ្ញានឹងសេចក្ដីឈ្លាសវាងវៃ ហេតុនេះ ត្រូវតែបណ្ដុះនិស្ស័យឲ្យល្អដែលគួរសំដែងទៅរកមនុស្សដទៃទៀត ។

បុគ្គលគ្រប់រូប សុទ្ធតែមាននិស្ស័យជាគ្រឿងពិសោធន៍ឲ្យឃើញច្បាស់ថា ល្អឬអាក្រក់ ឥតមានលក្ខណៈអ្វីដទៃឡើយ ។ និស្ស័យរមែងយោងលក្ខណៈដទៃៗ ទាំងអស់ឲ្យអណ្ដែតឡើងមកនៅលើសីសៈ ដូចជានិស្ស័យខាងសុភាពនឹងប្រឡេសប្រស, ទូលាយនឹងស្ងួតស្ងាញ, ទុនលំទោននឹងរឹងត្អឹង, ស្មោះត្រង់នឹងវៀចវេរជាដើម ជារបស់គឺយើងអាចដឹងច្បាស់បាន ក្នុងកាលដែលគេសំដែងឡើងចំពោះមនុស្សដទៃ តាមលំនាំអាការដែលគេប្រព្រឹត្តជានិច្ចសម្រាប់ជីវិត នឹងតាមសម្ដីសូរនៃពាក្យនិយាយគ្រប់ៗម៉ាត់ ព្រមទាំងតាមដំណើរការងារគ្រប់ៗចំណែករបស់ខ្លួនៗ

និស្ស័យល្អ ជាលក្ខណៈមានគុណតៃម្យ៉ាង, កាលបើមាននៅក្នុងខ្លួនអ្នកណាហើយ នឹងធ្វើអ្នកនោះឲ្យជាមនុស្សល្អរៀបរយ មានកិត្តិយសនឹងឈ្មោះសំឡេង ហើយអាចរាប់ថាជាគោលធម៌ជាប់ទាក់ទងគ្នានឹង

ប្រជាគមព្រមទាំងមនុស្សទូទៅ អាចការពារសមាគមរបស់ពួកមនុស្សឲ្យផុតចាកសេចក្តីអាក្រក់ និងការមិនមានរបៀបរៀបរយដែលជាសត្រូវបានផង ព្រោះមនុស្សមាននិស្ស័យល្អ សូម្បីជាអ្នកមិនមានជោគវាសនា ខ្សត់ទ្រព្យសម្បត្តិក៏ដោយ ក៏គង់អាចប្រើនិស្ស័យល្អរបស់ខ្លួន សម្រាប់ជាគ្រឿងចងភ្ជាប់ទឹកចិត្តរបស់អ្នកដែលមកសមាគមបាន បើទុកជាអ្នកនោះមាននិស្ស័យអាក្រក់ ក៏អាចឲ្យកើតការគោរពនិយមរាប់អានជ្រះថ្លាក្នុងខ្លួន និងកាន់យកជាទិដ្ឋានុគតិបានដែរ ។

ការបណ្តុះនិស្ស័យ គឺការតាំងខ្លួន ។ ការតាំងខ្លួន ទៅជាការសាងជាតិ ។ សូម្បីការសាងជាតិ ក៏ត្រូវតែតាំងខ្លួនជាមុន ។ ឯសេចក្តីសំខាន់របស់ការតាំងខ្លួន នៅត្រង់ការបណ្តុះនិស្ស័យ ។ ការបណ្តុះនិស្ស័យឲ្យល្អនោះ មិនចំពោះតែរូបបុគ្គលមួយៗ ទេ ត្រូវជាប់ទាក់ទងដល់ជាតិនិងប្រទេសផង ព្រោះថាការវាស់គុណភាពរបស់ជាតិប្រទេស មិនមែនវាស់តែនិស្ស័យរបស់មនុស្សអ្នកល្អមាំមួន ឬមនុស្សម្នាក់ៗ ប៉ុណ្ណោះឡើយ យើងត្រូវវាស់និស្ស័យទឹកចិត្តរបស់ពួកជនក្នុងជាតិទាំងអស់ ។ ពិតមែន! អ្នកប្រាជ្ញ ឬវិជ្ជបុរសដែលចេះជ្រៅជ្រះនោះ ជាប្រធាននៃកំឡាំងរបស់ប្រជាគម តែសូមកុំភ្លេចថា "សូម្បីពួករាស្ត្រ មានអ្នកស្រែជាដើម ក៏ជាកំឡាំងនិងជាទឹកចិត្តរបស់ជាតិឬជាឆ្អឹងខ្នងរបស់ប្រទេសដែរ" ។

ឋានៈរបស់ប្រទេស ជាតិ សាសនា ដែលអាប់ឱន មិនមែនព្រោះការគ្រប់គ្រងទេ, តាមពិត គឺព្រោះនិស្ស័យអាក្រក់របស់ប្រជាជន ។ បើប្រជាជនមិនបានទទួលការអប់រំដោយពេញចិត្តក្នុងការបណ្តុះនិស្ស័យល្អដើម្បីជួយខ្លួនឯងហើយ បើទុកជាការគ្រប់គ្រងនោះវិសេសយ៉ាងណាក៏ដោយ ក៏មិនអាចនឹងញ៉ាំងគេឲ្យអណ្តែតឡើងបានដែរ ។ ពិតមែន, ការគ្រប់គ្រង ទោះបីអាក្រក់យ៉ាងណា ក៏គង់មានផលអាក្រក់មិនស្មើនឹងនិស្ស័យអាក្រក់របស់ប្រជាជនដែលនៅក្រោមការគ្រប់គ្រងនោះឡើយ ព្រោះនិស្ស័យអាក្រក់ដែលទាញប្រជាជនឲ្យចុះទៅកាន់ទីទាបនោះ ជាការអាក្រក់ខ្លាំងក្លាណាស់ ។ ប្រទេស ជាតិ សាសនា ដែលដល់នូវសេចក្តីវិនាសបាត់បង់ទៅ តែងធ្លាក់នៅលើពួកពលរដ្ឋ ដែលមាននិស្ស័យអាក្រក់ដោយច្រើន ដូចជានិស្ស័យទុរយស វៀចវេរ និស្ស័យល្ងង់ខ្លៅ និស្ស័យខ្ជិលច្រអូស និស្ស័យខាងការឃើញតែប្រយោជន៍ផ្ទាល់ខ្លួននឹងនិស្ស័យខាងការប្រួលចិត្តបង្កកម្មអាក្រក់ផ្សេងៗជាដើម ។ សូម្បីឋានៈរបស់ប្រទេស ជាតិ សាសនា ដែលអណ្តែតខ្ពស់ឡើង ដល់ទីបំផុតតាមបំណង ក៏ព្រោះផលដែលប្រជាជនមាននិស្ស័យល្អជាសំខាន់ ។ សេចក្តីចំរើន សេចក្តីរុងរោចន៍ ការឈានទៅមុខ នឹងការមាំមួនរឹងប៉ឹងដំហរ នៃប្រទេស ជាតិ សាសនា មិនថាក្នុងនាទីឬករណីណាៗទេ តែងតែជាផលជាប់មកអំពីនិស្ស័យល្អរបស់ពលរដ្ឋជានិច្ច, តែពលរដ្ឋនឹងមាននិស្ស័យ

និស្ស័យល្អនោះ ក៏ព្រោះបានទទួលការអប់រំឲ្យចេះដឹងកន់កិច្ចបណ្ដុះនិស្ស័យឡើងដោយខ្លួនឯង ។ មនុស្សដែលមាននិស្ស័យល្អហើយ រមែងស្គាល់គុណសំដីរបស់ខ្លួនទឹងតែផ្សេងៗ ដោយទឹកចិត្តដ៏ជាក់លាក់ ចេះបណ្ដុះចិត្តខ្លួនឯង ដូចយ៉ាងឥស្សរជនចេះរក្សាខ្លួនឯងនឹងចេះធ្វើជានាយចៅហ្វាយលើខ្លួនឯងបានទៀត ។

កាលបើពលរដ្ឋ មាននិស្ស័យល្អនឹងមានវិជ្ជាគុណជាន់ខ្ពស់ហើយ រមែងងាយស្រួលដល់ការគ្រប់គ្រង, សូម្បីរបៀបនៃការគ្រប់គ្រង ក៏ដំណើរទៅតាមផ្លូវដ៏ខ្ពស់ គឺប្រើវិធីការតាមបែបគ្រប់គ្រងរបស់មនុស្សល្អនឹងមនុស្សឈ្លាស ។ បើពលរដ្ឋមាននិស្ស័យអាក្រក់នឹងល្ងង់ខ្លៅហើយ រមែងជាការលំបាកដល់កិច្ចគ្រប់គ្រង, ច្បាប់ទំលាប់នឹងរបៀបការគ្រប់គ្រងនោះ ក៏ត្រូវប្រើវិធីតាមបែបការគ្រប់គ្រងនៃមនុស្សអាក្រក់ នឹងមនុស្សល្ងង់ ។ ដូច្នេះ ការបណ្ដុះនិស្ស័យដែលជាកិច្ចធំបំផុត នៅត្រង់ការបណ្ដុះពួកជនឲ្យមាននិស្ស័យល្អទូទៅពេញប្រទេស ព្រោះជាគោលចារិកនៃការឈានដើរទៅកាន់អារ្យធម៌របស់ជាតិនោះ មាននិស្ស័យល្អរបស់ប្រជាជនទាំងអស់ជាបេះដូង ។

និស្ស័យល្អនេះ មានកម្លាំងខ្លាំងក្លាណាស់ លុះតែកម្លាំងកាយ ១០ ទើបស្មើនឹងកម្លាំងនិស្ស័យ ១ ។ សូមឲ្យមើលចុះ ! កម្លាំងវេងប៉ុង, ការឧស្សាហកម្ម នឹងអារ្យធម៌ បូរីវឌ្ឍធម៌របស់ជាតិ សុទ្ធតែ

ត្រូវការស្រ័យនិស្ស័យល្អរបស់ជនមួយរូបៗ ដែលរួមគ្នា ទៅជាពួកមួយរបស់ជាតិទាំងនោះ ៗ សូម្បីសន្តិសុខរៀបរយនឹងការមានសីលធម៌របស់ពួកជនខាងក្នុងប្រទេស ក៏ត្រូវស្រ័យនិស្ស័យល្អរបស់មនុស្សជាសំខាន់ដែរ ៗ ច្បាប់ទំលាប់នឹងរបៀបផ្សេងៗ របស់ប្រទេស មិនមែនជាមូលហេតុនាំឲ្យកើតនិស្ស័យឡើយ គឺជាផលកើតឡើងអំពីនិស្ស័យរបស់មនុស្សដោយត្រង់ ៗ និស្ស័យល្អនេះ កាលខ្លួនបានបណ្ដុះឡើងហើយ រមែងធ្វើឲ្យខ្លួនមានលក្ខណៈល្អ តាមបែបនៃនិស្ស័យដែលខ្លួនបណ្ដុះមកនោះ ដូចជាមនុស្សមានសម្មាគារវៈ សុបស្មៀម សុភាព ទន់ភ្លន់ទោនស្មោះត្រង់ សុចរិត កតញ្ញូ ស្រឡាញ់កក្តី ប្តូលចិត្តតែមានរបៀបរៀបរយ ចេះទទួលខុសត្រូវ ជួយខ្លួនឯង ដំកល់ខ្លួនត្រូវនឹងមានកិរិយាមារយាទល្អជាដើម ៗ

គប្បីប្រាប់បុះថា: ការបណ្ដុះនិស្ស័យ ជាការបង្ហាត់នូវអធ្យាស្រ័យឲ្យបរិសុទ្ធពេញលេញ គឺធ្វើអធ្យាស្រ័យឲ្យទន់ទៅក្នុងការធ្វើ និយាយនឹងគិត ដោយសុចរិត ។ ការធ្វើ និយាយ គិត ដោយសុចរិតនោះជាខ្លឹមសារសំខាន់របស់និស្ស័យដែលធ្វើឲ្យមនុស្សមានលក្ខណៈល្អ ។ ឯការមិនអប់រំនិស្ស័យវិញ ជាការបង្ហាត់អធ្យាស្រ័យទៅក្នុងចំណែកដ៏សាបសូន្យ គឺធ្វើឲ្យអធ្យាស្រ័យទន់ទៅក្នុងការធ្វើ និយាយ គិត ដោយទុច្ចរិត ។

ការធ្វើជាដើមដោយទុច្ចរិតនោះ ជាហេតុយ៉ាងខ្លាំងក្លារបស់និស្ស័យដែលធ្វើឲ្យមនុស្សមានលក្ខណៈអាក្រក់ ។

តាមពិត ការសោយសោក តែងកាត់ផ្តាច់នូវសេចក្តីរីករាយ, រដូវរងា តែងកាត់ផ្តាច់នូវលំអន្ទរដូវក្តៅ, ព្រះអាទិត្យ តែងកំចាត់បង់នូវងងឹត, ទោស តែងបំបាត់នូវគុណ, ការសាងនិស្ស័យឲ្យល្អ តែងកាត់ផ្តាច់នូវសេចក្តីវិបត្តិ, ឯការបណ្តោយឲ្យនិស្ស័យថោកទាប តែងបំផ្លាញនូវសិរីមង្គល ។ គ្រប់មនុស្ស សុទ្ធតែចង់បានល្អចង់បានទ្រព្យនឹងយសស័ក្តិ តែអ្នកប្រសប់ទើបបានទ្រព្យ, អ្នកវៀររបស់ស្ងួន ទើបបានសុខសម្រាន្ត, អ្នកមិនមានហេតុភ័យឈឺចាប់ ទើបមានសុខភាព, ឯអ្នកដែលសាងនិស្ស័យល្អវិញ តែងសម្បូណ៌ទៅដោយគុណ មាំមួនដោយទ្រព្យសម្បត្តិនឹងយសស័ក្តិ ថែមទាំងជាបុគ្គលអាចជួយខ្លួនឯង និងគ្រួសាររបស់ខ្លួនបាន ដរាបដល់អាចជួយជាតិ សាសនា របស់ខ្លួនក្នុងវេលាដែលត្រូវការបានទៀតផង ។

ដូច្នេះ យើងគប្បីតាំងចិត្តសិក្សារឿង “ការបណ្តុះនិស្ស័យ” ហើយខំបណ្តុះនិស្ស័យរបស់ខ្លួនឲ្យល្អតាមរឿងនេះចុះ ព្រោះរឿងនេះ ឥតបានជាប្រយោជន៍ ដល់អ្នកដែលគ្រាន់តែមើលឲ្យចេះដឹងហើយមិនប្រព្រឹត្តតាមនោះទេ លុះតែជនណាមួយ ចេះដឹងហើយខំប្រព្រឹត្តតាមផង ទើបអាចទទួលផលប្រយោជន៍អំពីរឿងនេះបាន ។ **(មាគ)**

# សព្ទបារាំងប្រែជាខ្មែរ

របស់

*គណៈកម្មការវប្បធម៌*

## លោកប៉ុញ - ឆាំត្រី អតីតតំណាងរាស្ត្រ រូបរួម

(តមក)

---

| | |
|---|---|
| Monôme = | ឯកធា |
| Binôme = | ទ្វិធា |
| Trinôme = | ត្រីធា |
| Polynôme = | ពហុធា |
| Expression algébrique = | បទសមោធានពីជគណិត |
| Rapport = | សម្មាភាគ |
| Proportion = | សម្មាមាត្រ |
| Donnée = | ទិន្នន័យ |
| Commentaire = | អត្ថាធិប្បាយ |
| Développement = | អភិវឌ្ឍន៍ |
| Conseil de discipline = | ក្រុមប្រឹក្សាវិន័យ |
| Négociation = | ការចរចា |
| Conseiller-d'Ambassade = | ទីប្រឹក្សាស្ថានឯកអគ្គរាជទូត |

Conseiller de Légation = ទីប្រឹក្សាស្ថានអគ្គរាជទូត

(១៧-១០-៤០)

Congrès = សមាជ

Clause = ខ

Termes = សំនួន, ខព្រមព្រៀង

Semi-œuvré = អឌ្ឍក្រឹត (ដែលគេធ្វើហើយឲ្យល្មម ប្រកបការគេទៅទៀតបាន)

(២៤-១០-៤០)

Coopération = សហប្រតិបត្តិការ

(២៧-១០-៤០)

Installation = ឋបនកណ្ឌ; ឋបនកម្ម

Entente = ការចុះសម្រុង

Entente cordiale = មិត្តភាពស្និទ្ធជិត

Cordialité = សនិទ្ធភាព

Alliance = សម្ពន្ធភាព

(៣-១១-៤០)

1°) premièrement = ១°) ត្រង់ទី ១

Possibilité = ការអាចប្រព្រឹត្តទៅបាន

(៧-១១-៤០)

Devise (Comptabilité) = រូបិយប័ណ្ណ

Deviser = និយាយគ្នាលេង

Facilité = សេចក្ដីស្រួល

En foi de quoi = ជាបន្ទាល់កងកិច្ចនេះ

Chancellerie = ស្ថានអធិការធិបតី

Chancelier = អធិការធិបតី

Homicide = ជនឃាត (ការសម្លាប់មហាជន)

Note verbale = លិខិតវាង (កំណត់ដោយលាយលក្ខណ៍អក្សរ
ឥតមានចុះហត្ថលេខាសម្រាប់ប្រើកងការទូត)

Nonce = សមណទូត (ឯកអគ្គរាជទូតរបស់សាសនា)

Légat du Pape = សមណប្រេសិតរបស់ប៉ាប

Accréditement = ការតាំងទូត

Diète = ទិនសភា (សភារបស់ប្រទេសខ្លះមានប្រទេស
ជប៉ុនជាដើម)

Blindé = រថក្រោះ

Scout-car = បុររថ (រថមើលការមុនគេ)

(១០-១១-៥១)

Exceptionnel = វិបុកពិជម្មតា

Compagnie de Quartier Général = កងអនុសេនាធំ នៃទីបញ្ជាការ

Caisse provinciale du Crédit Populaire = ហិបប្រាក់ប្រចាំខែត្រសម្រាប់ចងការឲ្យប្រជាជន

Mécanicien = យន្តការី

Canot-automobile de plaisance = កាណូតយន្តកំសាន្ត

Machine à vapeur = ម៉ាស៊ីនប្រើចំហាយ

Moteur de chaloupe = យន្តកប៉ាល់

(២៨ ១១-៥០)

Décompte = វិគណនី (ការកយមុខបរិមាណប្រាក់)

Brigadier de la P. M K. = អ្នកត្រួត ក. ទ. ខ. (អ្នកត្រួតនៃក្រុមតម្រួតទាហានខ្មែរ)

(១-១២-៥០)

Maréchal des Logis de la P. M. K. = ពលបាលនៃ ក. ទ. ខ. (ក្រុមតម្រួតទាហានខ្មែរ)

Etude (d'une question) = ការពិនិត្យគ្រាងការណ៍ (នៃបញ្ហា)

Objectif (adj.) = ជាយថាវត្ថុ (ដែលមានដំណើរទៅតាមហេតុ)

Conflit = ចំណោះ

Polémique = សង្គ្រាមប៉ាកកា

Subjectif = ជាអញ្ញថាវត្ត (ដែលដំណើរផ្សេងពីយថាវត្ត)

(៥-១២-៥០)

Assurer = រាប់រង

Affirmer = អះអាង

Garantir = ធានា

Statuer = អារកាត់, សំរេចសេចក្តី

Faire faillite = រលំ (ខាងជំនួញ)

Dons = ទាន, អំណោយ

Legs = អច្ច័យទាន (អំណោយរបស់បុគ្គលស្លាប់)

Spécialisation = ឯកទេសកម្ម

(៨-១២-៥០)

Insigne = លក្ខណសញ្ញា (គ្រឿងសំគាល់)

Tenue militaire = យោធាចរិយា (របៀបសណ្ដាប់ធ្នាប់ សំ-លៀកបំពាក់ទាហាន)

Habillement = សំលៀកបំពាក់, គ្រឿងតែងខ្លួន, ការតែងខ្លួន

Tenue matérielle des nouvelles recrues = សម្ភារៈបរិក្ខារទាហានថ្មី

Galon = ប៉ានស័ក្តិ

(១២-១២-៥០) (មាធរ)

# រឿងព្រេងភូមា

## លោក សាង-សាកែត លេខានុការ ក្រសួងហិរញ្ញវត្ថុ

ប្រែពីភាសាបារាំងមកជាខ្មែរ

(តចប់)

---

ក្នុងពេលនោះ យាយមេដោះរបស់នាងចេញមកហើយដោយមិនដឹងរឿងអ្វី បាននិយាយឲ្យនាងដោះចិញ្ចៀនមួយភ្លែត ដើម្បីឲ្យលោកមើលផង ។

លុះកាលណាភិក្ខុទទួលចិញ្ចៀនមកហើយ បានធ្វើខ្លួនទៅជាសត្វក្អែកខ្មៅមួយយ៉ាងធំ ហើយហើរទៅនៅក្នុងកោះមួយយ៉ាងឆ្ងាយ កណ្ដាលមហាសមុទ្រ ដែលគ្មានអ្នកណាមួយអាចទៅតាមបាន ។ វាទៅតាំងប្រាសាទមួយយ៉ាងល្អឆើតឆាយ មានដំបូលប្រាំមួយជាន់ ។

លុះដល់បុរសត្រឡប់មកប្រាសាទវិញ បានដឹងរឿងក៏កើតទុក្ខជាអនេក និយាយទៅកាន់ភរិយាថា "តើហេតុយ៉ាងណាបានជាអូនបង្ហាញចិញ្ចៀនឲ្យវាមើល? មិនចាំពាក្យបណ្ដាំរបស់បងសោះ! ឥឡូវនេះអូនឃើញទេ? ភិក្ខុបានចិញ្ចៀនហើយរត់ទៅនៅកណ្ដាលសមុទ្រ ។ កន្លែងនោះគ្មានអ្នកណាទៅដល់ទេ បងអស់សង្ឃឹមហើយពីថ្ងៃនេះតទៅ" ។ បុរសឃើញភរិយាយំទឹកភ្នែកហូរហោម ក៏មានចិត្តអាណិតមេត្តានាងជាពន់ពេក បានលួងលោមបីបមថ្នាក់ថ្នមអង្អែលនាង ហើយបានកំណត់ទុក

ក្នុងចិត្តថា : "ការណ៍ពិតនោះ គឺកំហុសរបស់ខ្លួនឯងដោយហេតុព្រើល ប្រគល់វត្ថុដ៏ថ្លៃថ្លានោះ ទៅស្រីដ៏ទន់ខ្សោយប្រាជ្ញា, ធ្វើយ៉ាងនេះ គឺបង់ឲ្យចិញ្ចៀនបាត់វិនាសអន្តរាយ" ។ បុរសព្រួយចិត្តពន់ពេក គំនិតនឹងវិញ្ញាណតែងរេរត់ទៅរករបស់ដែលបាត់ជានិច្ច ។

ប៉ុន្តែរឿងនេះ អស់លោកអ្នកគង់ជ្រាបក្នុងកាលជាខាងក្រោយវិញទេ ទុក្ខព្រួយរបស់បុរសនេះ មិនមែនបេះតែនៅនឹងដដែល ដូចបុរសបានទឹកស្មាននោះឡើយ ។ ថ្ងៃមួយមានហ្វូងស្រីទេពអប្សរនៅនាស្ថានសួគ៌ចុះមកមុជទឹកលេងសប្បាយក្នុងត្រពាំងមួយ ដ៏មានទឹកថ្លាត្រចះត្រចង់ លំអដោយផ្កាឈូករីករហង់នៅជិតទីប្រាសាទរបស់បុរស ។ មុននឹងចុះមុជទឹកនោះ ស្រីទេពអប្សរទាំងអស់ដោះកងកដាក់លើច្រាំង ។

ឆ្មាដើរលេងជិតទីនោះ ឃើញកងកល្អប្រសើរក្រៃពេក, មួយទៀតឃើញម្ចាស់របស់ខ្លួនមានទុក្ខព្រួយផង, ឆ្មាមានគំនិតមួយភ្លាម គឺឆ្លៀតយកឱកាសនោះ ដើម្បីធ្វើឲ្យបុរសជាម្ចាស់បានសប្បាយចិត្តវិញ ។ លុះគិតដូច្នោះហើយ ឆ្មាប្រមូលកងកទាំងអស់យ៉ាងប្រញាប់ប្រញាល់ រួចយកទៅលាក់នៅគល់ឈើមួយកណ្ដាលព្រៃធំ ។ កំពុងតែមុជទឹក ស្រីទេពអប្សរ បានឃើញឆ្មាបោលយ៉ាងលឿនដូច្នោះ ក៏នាំគ្នាឈប់មុជទឹកទាំងអស់ ហើយរត់ទៅសំពះអង្វរឆ្មា ដែលត្រឡប់មកអង្គុយលើមាត់ច្រាំងវិញ ។

បើសិនណាឆ្មាជាមនុស្សវិញ   មិនអាចទប់ចិត្តបាននឹងសេចក្ដីអន្ទូររបស់ស្រីទេពកញ្ញា ដែលមានសក់ចងជាកួនរែងៗ ហើយដែលគ្រាប់ករីជាប់នៅក មើលទៅល្អដូចគ្រាប់ត្បូងពេជ្រដែករចរណៃ ជាប់នៅលើស្បៃដ៏ស្អាតវិចិត្រ គួរឲ្យមានបំណងចង់មេត្រីណាស់ ។ ប៉ុន្តែនេះ ហេតុតែឆ្មាមានចិត្តទៀងត្រង់ល្អ ហើយគ្មានគ្រោងការណ៍អ្វីមួយប្រាកដក្នុងខ្លួន ។ ឆ្មាអង្គុយនៅទីនោះធ្វើពុយមុយមើលមុខស្រីកញ្ញា ដែលអន្ទូរដោយសំឡេងយ៉ាងផ្អែមពីរោះ ដូចមានតទៅនេះ "ឱ! អ្នកបងឆ្មាអើយ! កងកអស់នោះសម្រាប់តែទេវតាទេ ឯមនុស្សលោកមិនត្រូវសោះ, ហេតុដូច្នេះសូមឲ្យម្ចាស់បងអាណិតខ្ញុំទៅ ឲ្យខ្ញុំវិញមក" ។ ឆ្មាឆ្លើយថា "នែស្រីទេពអប្សរទាំងឡាយ! យើងសុខចិត្តឲ្យកងកទាំងអស់វិញក្នុងគ្រាឥឡូវ យើងគ្មានត្រូវការទេ ប៉ុន្តែយើងសុំឲ្យ អ្នកសំដែងសិល្បវិជ្ជាធ្វើជាផ្លូវមួយ ពីទីនេះទៅដល់កោះតូចមួយដែលនៅកណ្ដាលសមុទ្រ ព្រោះព្រាហ្មណ៍ម្នាក់បានលួចចិញ្ចៀនរបស់ចៅហ្វាយនៃយើងរត់ទៅពួននៅទីនោះ, កុំបាច់ដដែកច្រើន, លុះតែធ្វើដូចពាក្យយើង ទើបយើងសុខចិត្តឲ្យកងកវិញ" ។

ស្រីទេពអប្សរក៏លើកដៃឡើងធ្វើជាថ្នល់មួយតាមកាលបុរាណ ពីព្រោះកាលណោះ គេមិនចាំបាច់ស្ពានទេ ។ លុះធ្វើបានដូចបំណងហើយ នាងក៏ត្រឡប់ទៅស្ថានសួគ៌វិញដោយរីករាយ ពីព្រោះនាងបានកងកវិញគ្រប់ៗគ្នា ។

ឆ្មាដើរយ៉ាងលឿនតាមផ្លូវថ្មល់នោះ, លុះទៅដល់កោះនោះហើយ បានឃើញព្រាហ្មណ៍ដេកលក់នៅក្នុងប្រាសាទ, ឆ្មាសង្កេតមើលឃើញចិញ្ចៀនដ៏វិសេសនៅក្នុងម្រាមដៃព្រាហ្មណ៍ ។ ឆ្មាខំអង្គិលដោះចិញ្ចៀននោះបន្តិចម្តងៗ ដោយមិនឲ្យព្រាហ្មណ៍ភ្ញាក់សោះ ។ លុះបានចិញ្ចៀនហើយឆ្មាត្រឡប់មកវិញភ្លាម ។

ឆ្មាយកចិញ្ចៀននោះទៅប្រគល់ដល់ដៃបុរសដែលជាចៅហ្វាយរបស់ខ្លួន ដោយក៏មានចិត្តត្រេកអរជាទីបំផុត ហើយនិយាយថា: "ខ្ញុំសងគុណចៅហ្វាយម្ចាស់ដោយសារចៅហ្វាយម្ចាស់មានគុណនឹងខ្ញុំ, លោកបានចំណាយប្រាក់អស់ជាច្រើនទិញខ្ញុំ, ឯដំឡៃដែលលោកទិញខ្ញុំនោះថ្លៃមួយរយដងជាងដំឡៃពិតរបស់ខ្ញុំ, រួចតាំងពីនោះមក លោកបានបីបាច់ថែរក្សាខ្ញុំជានិច្ច" ។

បុរសតែទៅប្រាប់មហេសី ។ ព្រះនាងមានព្រះទ័យត្រេកអរពន់ពេក, ចំណែកខាងកិត្តុលាមកអកុសល ធ្លាក់ក្នុងសមុទ្រលង់ទឹកស្លាប់បាត់ទៅ ។

លុះយូរបន្តិចក្រោយមក មានចោរកំណាចមួយពួកចូលទៅក្នុងប្រាសាទ កណ្តាលរាត្រីងងឹត ដោយមានបំណងចង់សម្លាប់បុរសដើម្បីយកចិញ្ចៀន ។ ប៉ុន្តែក្នុងពេលនោះ ឆ្កែកំពុងឈរយាមល្បាត កាលឃើញពួកចោរក៏លោតទៅខាំមេចោរដួលស្លាប់នៅកន្លែង ហើយពួស

ខ្មោចទៅបោលក្នុងអណ្តូងមួយក្នុងសួនច្បារ ។ ឯអស់ពួកកូនចោរទាំងពួង លុះឃើញដូច្នោះ មានចិត្តគិតភ័យនាំគ្នារត់ ខ្លះត្រូវបួសនៅជើង ដោយអំណាចចង្កូមនៃឆ្កែ ។

លុះព្រឹកឡើង ឆ្កែនិយាយប្រាប់បុរសដែលតែងអង្អែលអ្នករាល់ព្រឹកថា : "យប់មិញខ្ញុំមិនបានដេកលក់ទេ ពីព្រោះខ្ញុំមានការធ្វើច្រើនណាស់" ។ បុរសក៏ឈ្ងល់សួរ, ឆ្កែក៏និយាយថា : "មានចោរបីនាក់លួចចូលក្នុងសួនច្បារ ដោយបានលោតផ្លោះរបងកំពែងប្រាសាទ ប្រាថ្នានឹងចង់មកសម្លាប់ម្ចាស់ ប៉ុន្តែខ្ញុំបានខាំសម្លាប់មេវា រួចកូនចោរគិតភ័យរត់បែកខ្ចាត់ខ្ចាយរៀងខ្លួន ខ្ញុំក៏បានពាំយកខ្មោចទៅបោលក្នុងអណ្តូង មានទាំងស្នាមនៅកន្ទឹងកាំបិតស្ទៀតជាប់នៅដៃអស្តុកនោះផង" ។ រួចឆ្កែបន្ថែមសេចក្តីថា : "ខ្ញុំបានជួយសង្គ្រោះចៅហ្វាយនេះ ថ្ងៃក្រោយខ្ញុំជួយទៀត ពីព្រោះចៅហ្វាយបានប្រព្រឹត្តល្អនឹងខ្ញុំ" ។ បុរសឆ្លើយថា : "អើ! គេចង់ព្យាបាទខ្ញុំ ដោយខ្ញុំបានជួយប្រាក់មួយរយណែនឲ្យអ្នក, គេចង់លួចទ្រព្យសម្បត្តិខ្ញុំ គេចង់ហូតជីវិតខ្ញុំ ក្នុងពេលដែលខ្ញុំកំពុងក្រេបបីតិក្នុងប្រាសាទនេះ, ខ្ញុំអរគុណនឹងសត្វទាំងបីដែលបានជួយខ្ញុំនេះ" ។ ថាហើយបុរសចូលទៅក្នុងព្រៃជ្រៅ យកក្របីព្រៃមកឲ្យនៅគេហស្ថានរបស់អ្នកវិញ ដើម្បីបីបាច់ថែរក្សាដូចសត្វទាំងពីរទៀត ។

ប៉ុន្តែលុះយកមកបំបាច់ក្បាលជាមួយគ្នាយូរទៅ សត្វទាំងបីកើតប្រណែនគ្នា ៗ ម្នាក់ៗ ចង់ឲ្យម្ចាស់របស់ខ្លួនយកទៅជាមួយ ក្នុងសួនច្បារក្ដី ក្នុងពេលដើរលេងក្ដី ក្នុងផ្ទះក្ដី ឬទៅទីណាក្ដី ៗ

ក្របីព្រៃទាមទារឲ្យម្ចាស់ក្បាលខ្លួនជាងគេ ដោយសារបានជូនចិញ្ចៀនមួយ ដែលជាដើមកំណើតនៃទ្រព្យធនធានទាំងអស់នោះ ៗ ឆ្មាទាមទារដូចក្របីព្រៃដែរ ដោយអាងថាខ្លួនបានប្រើមធ្យោបាយយ៉ាងប៉ិនប្រសប់ ឲ្យស្រីទេពអប្សរធ្វើផ្លូវឲ្យខ្លួនទៅយកចិញ្ចៀននោះពីបព្វជិតលាមកមកវិញ ដោយគ្មានខ្លាចគ្រោះថ្នាក់ទាំងពួងតាមផ្លូវនោះសោះ ៗ ឯចំណែកខាងឆ្កែវិញពោលថា: "ការណ៍ដែលពិឃាតចោរ ហើយធ្វើឲ្យកូនចោរតក់ខ្លាត់ខ្លាយជាការណ៍ឥតប្រយោជន៍ទេឬ? ខ្ញុំមិនមែនការពារត្រឹមតែទ្រព្យសម្បត្តិរបស់ចៅហ្វាយខ្ញុំទេ ខ្ញុំការពារដល់ទៅជីវិតរបស់លោកទៀត, ហេតុដូច្នេះ មានតែខ្ញុំមួយទេ ដែលលោកត្រូវបីបាច់ក្បាលជាងគេទាំងអស់" ៗ ការណ៍ដែលប្រកែកប្រណាំងនេះ ចេះតែមានជំលោះរឿងៗ គ្មានស្រាកស្រាន្តសោះ, ឯសត្វទាំងបី គ្មានអ្នកណាមួយព្រមចុះចាញ់អ្នកណាមួយសោះ ៗ ដល់ក្រោយមក ទាំងអស់គ្នាក៏ព្រមព្រៀងគ្នាទៅប្ដឹងដល់ព្រះនាងខត្តិយានីធូដាម្នាសារី "Thoudamna Sâri" ៗ ព្រះនាងអង្គនេះ គង់នៅក្នុងស្រុកម៉ាដារី (Madari) ជាមួយឪពុករបស់ព្រះនាង នៅក្នុងប្រាសាទមួយយ៉ាងស្កុតស្កម្ភ ដែលមានសសរមួយធំនៅចំកណ្ដាលដូចប្រាសាទទាំងពួង ដែលគេតែងទុកថ្វាយបុត្រីស្ដេចផែនដី ៗ

ព្រះនាងចេះចាំនូវច្បាប់ទាំង ១០ របស់អង្គក្សត្រិយ៍ ទីងស័លទាំងប្រាំក្នុងគម្ពីរ : ឯច្បាប់ ដូច្បរេណី ច្បាប់ខ្មែរ សៀវភៅបរមត្ថវិជ្ជា សៀវភៅចរិយាសាស្ត្រ មិនកំបាំងពីព្រះនាងឡើយ ។ សន្តិចរិយារបស់ព្រះនាងល្អល្បីសុះសាយគ្រប់ដំបន់ ហើយអ្នកចេះដឹងគ្រប់ជាតិនៅនាលោកនេះតែងនាំគ្នាមករកព្រះនាងគ្រប់ ៗ គ្នា នៅសាលាដំបូងរបស់ព្រះនាង ដើម្បីចង់ដឹងបញ្ហា ដែលចេញហូរក្លាម ៗ ពីមាត់ព្រះនាង ។

ឯសត្វទាំងបីនោះ ទៅរកព្រះនាងនេះ សូមឲ្យព្រះនាងកាត់សេចក្តីឲ្យ ។ ក្នុងពេលនោះ ក្របីព្រៃនិយាយមុនគេថា : "ចៅហ្វាយខ្ញុំបាទបានទិញខ្ញុំបាទអំពីមនុស្សកំពេលម្នាក់ ថ្លៃមួយរយរៀល ; រួចមាតារបស់ចៅហ្វាយខ្ញុំបាទនេះ បានបីបាច់ចិញ្ចឹមខ្ញុំបាទយ៉ាងហ្មត់ចត់ រួចលោកបានលែងឲ្យខ្ញុំបាទរួចខ្លួនទៅនៅក្នុងព្រៃផង ; ដោយអំពើកុសលនេះ ខ្ញុំបាទមិនភ្លេចគុណលោកទេ ខ្ញុំបាទបានយកចិញ្ចៀនមួយមកសងគុណលោក, ដោយសារចិញ្ចៀននេះ ក្នុងពេលរាត្រីស្ងាត់ លោកបានបង្កើតប្រាសាទមួយយ៉ាងល្អធេតធាយនៅមុខផ្ទះរបស់លោក រួចបានរស់នៅយ៉ាងសុខសប្បាយជាមួយបុត្រីព្រះមហាក្សត្រិយ៍ ដែលលោកបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាយ៉ាងខ្ពង់ខ្ពស់, អាស្រ័យហេតុនេះ មានតែខ្ញុំមួយទេ ដែលចៅហ្វាយខ្ញុំបាទ ត្រូវបីបាច់ជាងគេទាំងអស់" ។ រួចដល់វេនឆ្មា ។ ឆ្មាអធិប្បាយយ៉ាងវែងឆ្ងាយជំរាបព្រះនាងខត្តិយានី ដែល

ប្រុងស្តាប់យ៉ាងម៉ាំមួនអំពីរឿងព្រាហ្មណ៍កំណាច នឹងដំរិះយ៉ាងប៉ិនប្រសប់ដែលអ្នកបានប្រើក្នុងពេលនោះ លុះត្រាតែយកចិញ្ចៀនបានមកវិញ ។ ក្នុងទីបំផុតឆ្មាជំរាបថា "បើសិនណាជាខ្ញុំមិនបានលួចកងករបស់ស្រីទេពអប្សរទេ ទ្រព្យសម្បត្តិរបស់ម្ចាស់ខ្ញុំបាទមុខជារលាយសូន្យអស់ពុំខាន" ។ លុះមកដល់វេនឆ្កែវិញ ឆ្កែដើរទៅមុខដោយឥតកក់ស្លុត ហើយនិយាយថា: "សូមព្រះនាងជ្រាប ! មានតែខ្ញុំទេដែលមានគុណជាងគេ, កាលដែលចោរចូលមកលួចចិញ្ចៀនរបស់ចៅហ្វាយខ្ញុំបាទ ខ្ញុំបាទលោតទៅខាំបំពង់កមេចោរ ដែលទទួលមរណភាពភ្លាមៗនៅមួយកន្លែង, ឯពួកកូនចោរកើតភ័យរត់ខ្វាត់ខ្វាយទាំងអស់, ហេតុដូច្នោះ ខ្ញុំបាទជួយមិនត្រឹមតែទ្រព្យសម្បត្តិរបស់ចៅហ្វាយខ្ញុំបាទទេ ខ្ញុំជួយទាំងជីវិតរបស់លោកថែមទៀត, ឯទ្រព្យសម្បត្តិអស់នេះ មានប្រយោជន៍អ្វី បើសិនណាជីវិតរលត់ផុតបាត់ទៅនោះ" ។

ការប្ដឹងផ្ដល់ក៏ផុតប៉ុណ្ណេះ, ព្រះនាងខត្តិយានីយកដៃប្រត់ថ្ពាល់ដ៏ល្អឆើតឆាយរបស់ព្រះនាង ។ ព្រះនាងគិតយ៉ាងយូរ នេះជាធម្មតារបស់ព្រះនាង កាលណាមានការលំបាកយ៉ាងដូច្នេះ ។ រួចព្រះនាងបញ្ចេញវាចាយ៉ាងទន់ភ្លន់ថា: "ឆ្កែបានជួយជីវិតរបស់ម្ចាស់គេ ដោយបានសម្លាប់ពួកចោរកំណាច, ហេតុដូច្នោះ ឆ្កែត្រូវតែបានកន្លែងលេខមួយ, ប៉ុន្តែខ្ញុំសូមឱកាសយ៉ាងខ្ពង់ខ្ពស់នៅចំពោះមុខអ្នកទាំងអស់គ្នាថា ការកាត់

សេចក្ដីនេះ គ្មានបន្ទុយបន្ទោកមិត្តរបស់ក្អែកទាំង ២ ទៀតទេ ព្រោះអ្នកណាក៏មានចិត្តកតញ្ញូដល់ចៅហ្វាយរបស់ខ្លួនដែរ ” ។

ឯរឿងដែលលោកគ្រូអាចារ្យនិទានឲ្យសិស្សទាំងបួននាក់ស្ដាប់នោះចប់តែប៉ុណ្ណោះ ។ រួចហើយសិស្សទាំងបួននោះចេញចាកពីសាលាទៅកាន់វត្តសង្ឃារយើងនេះរៀងៗខ្លួនទៅ ។

រឿងនេះជាដំបូន្មានមួយយ៉ាងប្រពៃ ដែលបង្ហាញឲ្យឃើញថា មនុស្សយើង ដោយធម្មជាតិនឹងដោយបញ្ញា ជាអ្នកមានឋានៈខ្ពង់ខ្ពស់ជាងសត្វ ។ ប៉ុន្តែអំពើដែលយើងប្រព្រឹត្តទៅនឹងសត្វនោះ មិនមែនជួបប្រទះនឹងសេចក្ដីល្មើសគុណទេ ហើយជាករណីយកិច្ចមួយយ៉ាងវិសេសរបស់មនុស្ស ឲ្យរក្សាសត្វដោយមុទុតា នឹងដោយមេត្តា ។

ចប់

ខ្មែរបន្ទោកខ្មែរ

ការពេញចិត្តប្រើអក្សរនឹងភាសានៃបរជាតិ ឈ្មោះថាបង្អាប់អក្សរនឹងភាសារបស់ខ្លួនឯង ទាំងជាហេតុឲ្យបរជាតិមានឥស្សរភាពលើប្រទេសខ្លួនផង, រឹតគួរឲ្យខ្មាសជាតិគេអ្វីម្ល៉េះ ។

យ. អ.

រឿងសាមកុក

កណ្ឌទី ៨

# អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

លីឈុយ តុយគី តបថា មហាឧបកជប្រព្រឹត្តបទកំហុស ឯងក៏ចុះទោសប្រហារជីវិតទៅហើយ តែយើងទាំង ៤ នាក់មានសំបុត្រមកអង្វរលន់តួខ្លួនសុំចូលធ្វើការជាមួយវិញ ហេតុអ្វីខ្លួនមិនព្រមលើកទោសសន្តោសប្រណី ត្រឡប់មានសេចក្តីព្យាបាទឲ្យចាប់យើងសម្លាប់ទៀត តើយើងខុសព្រោះហេតុអ្វី? ។ អងអ៊ុនស្រែកគំហកថា ដែលអញមិនទទួលយកឯងទាំង ៤ នាក់ទុកធ្វើរាជការផងនោះ ព្រោះឯងជាបក្សពួកអាក្សត់ផែនដី អញក្រែងឯងធ្វើបក្សាត់ឲ្យអន្តរាយផែនដីទៀត ឥឡូវឯងប្រាថ្នាចង់ធ្វើអ្វីក៏ធ្វើឆាប់ទៅចុះ អញមិនមែនខ្លាចស្លាប់ទេ ។ លីពុយ

គុយគីខឹងខ្លាំងណាស់ក៏ហូតគ្រឹបកាប់អង់អ៊ុនស្លាប់ ហើយឲ្យទាហានទៅចាប់ភរិយាបុត្រញាតិសន្តានសម្លាប់អស់ទៅទៀត ៗ ឯអាណាប្រជានុរាស្ត្រក្នុងស្រុកក្រុងវេលានោះ លុះដឹងថាអង់អ៊ុនស្លាប់ហើយ ទើបនាំគ្នាទួញយំដំនុក ដោយសារអាល័យស្រឡាញ់អង់អ៊ុនពន់ប្រមាណណាស់ ៗ

លីឈុយ គុយគី គិតគ្នាថា យើងធ្វើការចូលមកដល់ទីនេះហើយ នឹងលះបង់ទៅវិញមិនបានទេ ត្រូវតែគិតយករាជសម្បត្តិហើយសម្លាប់ព្រះចៅហៀនតេចេញទើបស្រួល ៗ តៀវចេ ហួនតៀវឃាត់ថា លោកនឹងធ្វើឲ្យចលាចលដល់ព្រះចៅហៀនតេនោះ យើងមិនបានយល់ព្រមផងទេ ព្រោះចៅហ្វាយខែត្រ ៗ ក្រៅពាំងអស់នឹងអាណាប្រជានុរាស្ត្រ មិនមែនចូលចិត្តនឹងឲ្យធ្វើដូច្នេះឡើយ បើយើងធ្វើហើយគង់នឹងលើកកងទ័ពពីគ្រប់តំបន់ ចូលមកតតាំងច្បាំងនឹងយើង យ៉ាងអធិកអធមមិនខាន យើងមុខជានឹងរកទីបង្អែកទប់ទល់ពុំបាន បើដូច្នេះត្រូវតែយើងបបួលគ្នាចូលទៅក្រាបសំពះគាល់ព្រះចៅហៀនតេ ទូលសុំធ្វើរាជការជានាហ្មឺនធំក្នុងក្រុង នឹងបានគិតអែបព្រះតម្រាស់ឲ្យហៅចៅហ្វាយខែត្រចូលមកហើយកាប់សម្លាប់ចេញ រាជសម្បត្តិគង់នឹងបានមកយើងដោយងាយ ៗ លីឈុយ គុយគីលុះបានស្តាប់ហើយឃើញថាត្រូវ ទើបនាំតៀវចេ ហួនតៀវចូលទៅគាល់ ៗ

ព្រះចៅហៀនតេទ្រង់ត្រាស់សួរលីឈុយ គុយគីថា ពីថ្ងៃមុនខ្លួនប្រាប់យើងថានឹងសុំយកខ្លួនអង់អ៊ុន បើបានហើយនឹងត្រឡប់លើកទ័ពទៅ

វិញ ឥឡូវខ្លួនសម្លាប់អង់អ៊ីនបានហើយ ហេតុម្តេចមិញទើបមិនលើកទ័ព ចេញទៅ ឯងចង់នៅប្រាថ្នាអ្វីទៀត? ។ លីឈុយ គុយគី ក្រាបទូល ថា កាលពីថ្ងៃមុនទូលព្រះបង្គំជាខ្ញុំបានធ្វើរាជការមានបំណាច់នឿយហត់ ក្នុងផែនដីព្រះករុណា តែមិនមាននរណានឹងគិតទូលព្រះអង្គឲ្យទ្រង់ជ្រាប ទើបព្រះអង្គមិនប្រទានយសស័ក្តិដល់យើងខ្ញុំ ឥឡូវនេះ យើងខ្ញុំទាំង ៤ នាក់ សូមចូលមកស្វាមីភក្តិ ធ្វើរាជការជានាហ្មឺនក្រោមល្អងធូលីព្រះបាទ, បើព្រះអង្គទ្រង់ព្រះរាជានុញ្ញាតប្រោសព្រះរាជទានតាមប្រាថ្នាហើយ ទូលព្រះបង្គំជាខ្ញុំនឹងលើកទាហានចេញពីព្រះរាជវាំងទៅវិញ ។

ព្រះចៅហៀនតេមានព្រះរាជឱង្ការត្រាស់ថា ដែលខ្លួនទាំង ៤ នាក់ ចូលចិត្តចង់ធ្វើនាហ្មឺននោះ តើចង់ធ្វើតំណែងអ្វីឲ្យថាមកចុះ ។ លីឈុយ គុយគី តៀវបេ ហ្វូនតៀវប្រឹក្សាគ្នាហើយ ទើបសរសេរជាសំបុត្រថ្វាយ ព្រះចៅហៀនតេៗ ទតឃើញសេចក្តីសំបុត្រនោះថា លីឈុយសុំជាទី "គីបុងគុន" គឺសុំជានាយទាហានធំខាងក្នុង ហើយជាអ្នកសម្រេចរាជការផង, គុយគីសុំជាទី "ហាបុងគុន" គឺជានាយទាហានធំខាងក្រោយហើយ ជាទីតាំងហ្វាងនាហ្មឺនទាំងពួងផង, តៀវបេនឹងហ្វូនតៀវជានាយទាហាន ឆ្វេងស្តាំ ។ ព្រះចៅហៀនតេក៏ទ្រង់ប្រោសប្រទានតាមសុំ ។ ឯលីឈុយ គុយគី លុះបានទទួលព្រះរាជត្រាស់ហើយ ក៏ចេញមកនៅក្រៅព្រះរាជវាំង ទើបប្រឹក្សាគ្នាថា "ស្រុកហាងឡុងនោះ ជាស្រុកមុខគយនឹងទុក

ចិត្តដល់ពួកស្រីមិនបាន" ទើបចាត់ឲ្យតៀវបេទឹង ហួនតៀវ លើកទាហាន
ទៅនៅរក្សា ៗ ឯលីបង់ទឹងអង់ហាន់ដែលបើកទ្វារស្រុកឲ្យកងទ័ពចូល
ទៅនោះ ក៏តាំងឲ្យឡើងទៅជានាហ្មឺនមានតំណែងក្នុងរាជការ ; បណ្ដា
ទាហានដែលមានសតិបញ្ញា ក៏តាំងឡើងជានាហ្មឺនទាំងអស់ ហើយឲ្យ
ទាហានទៅស៊ើបពិនិត្យរើសយកឆ្អឹងតាំងតុះ មកតែងការសពរបៀបមហា·
ឧបរាជ ហើយឲ្យហែចេញទៅទឹងកប់សពទុកតាមទំនៀម ៗ ក្នុងខណៈ
កំពុងរៀបបញ្ចុះសពនោះ ក៏បណ្ដាលឲ្យកើតខ្យល់ព្យុះសង្ឃរាជាខ្លាំង
ណាស់ កើតជាផ្គររន្ទះភ្លៀងធ្លាក់ទឹកជោរជន់លិចផែនដី ជំរៅប្រហែល
២ ហត្ថ ហើយថែមមានទាំងរន្ទះបាញ់ប្រស់លើសព ឯឆ្អឹងដែលកប់ខ្ទាត
ខ្ទាត់ចេញអស់, លុះភ្លៀងស្ងប់ហើយ លីឈុយឲ្យរើសប្រមូលឆ្អឹងមក
បញ្ចុះទៀត ភ្លៀងរន្ទះក៏បាញ់ប្រស់ខ្ទាត់ខ្ទាយឆ្អឹងអស់ទៅទៀត លីឈុយ
ក៏ឲ្យរើសមកបញ្ចុះទៀតជាច្រើនគ្រា ភ្លៀងក៏បង្អុរចុះមកលិចផែនដី
អសនីរន្ទះក៏បាញ់ប្រស់ឆ្អឹងតាំងតុះនោះទាល់តែខ្ទេចខ្ទីជាធូលីអស់ទៅ ទឹង
រើសយកមកទៀតពុំបាន. ៗ ដែលកើតហេតុទាំងនេះ ព្រោះតាំងតុះធ្វើ
ការអាក្រក់ក្បត់ផែនដី សម្លាប់មនុស្សប្រុសទឹងស្រីជាច្រើនណាស់ ៗ
លីឈុយ គុយគីអស់តំរិះប្រាជ្ញាត្រឡប់ចូលទៅក្រុងវិញ ៗ តាំងពីនោះ
តមក លីឈុយ គុយគី រិតតែធ្វើការកំរើកតាមអំពើចិត្ត អាណាប្រជា·
នុរាស្ត្រក៏បានសេចក្ដីក្ដៅក្រហាយខ្លាំង ៗ លីឈុយ គុយគី យកម៉ាស៊ុ

ប្រាក់ទៅសូកចិត្តខន្ទីដែលរក្សាព្រះចៅហៀនតេហើយផ្តាំថា បើឮព្រះចៅហៀនតេត្រាស់ពីសេចក្តីល្អអាក្រក់ប្រការម្តេច សុំឲ្យនាំសេចក្តីនោះទៅប្រាប់ឲ្យដឹងផង ។

ក្នុងសម័យនោះ ព្រះចៅហៀនតេនៅជាព្រះកុមារណាស់ ទឹងត្រាស់បង្គាប់ការអ្វីជាផ្លូវរាជការក៏ពុំស្រេចដាច់ខាត, រាជការផែនដីក៏ត្រឡប់ត្រឡិនក័ន្តប្រែទៅ, បណ្តានាហ្មឺនមុខមន្ត្រីក្នុងក្រុង ក៏សឹងនៅក្រោមបង្គាប់បញ្ជាលីឈុយគុយគីទាំងអស់ ។ ឯលីឈុយគុយគីក៏ឲ្យគេដូហ៊ីដែលជានាហ្មឺនក្រៅរាជការនោះ មកតាំងជានាហ្មឺនក្នុងរាជការជាទីប្រឹក្សាវិញ ។

ចំណែកម៉ាថេងចៅហ្វាយស្រុកសេលៀង នឹងហាន់ស៊ុយចៅហ្វាយស្រុកប៉េងជីវប្រឹក្សាគ្នាថា "ឥឡូវនេះ លីឈុយ នឹងគុយគីបានជានាហ្មឺនធំក្នុងស្រុកក្រុង ធ្វើការទុច្ចរិតប្រព្រឹត្តអាក្រក់ដូចគ្រាតាំងតុះ បើដូច្នោះចាំយើងនឹងកំចាត់វាចេញ ទើបនឹងបានសេចក្តីសុខក្នុងស្រុកទេសតទៅ" គិតហើយក៏ធ្វើសំបុត្រ ១ ច្បាប់ទៅដល់ម៉ាហ៊្វូ, ១ ច្បាប់ទៅដល់តុងសៀវ, ១ ច្បាប់ទៅដល់ឡាឈៀវ, អ្នកទាំង ៣ នេះជានាហ្មឺនខ្ញុំរាជការចាស់នៅក្នុងក្រុង ។ សេចក្តីសំបុត្រនោះថា "លីឈុយគុយគីធ្វើការទុច្ចរិតប្រព្រឹត្តអាក្រក់ សព្វថ្ងៃអាណាប្រជានុរាស្ត្រខែត្រក្រៅក្តៅក្រហាយដូចគ្រាតាំងតុះ បើដូច្នេះ សុំឲ្យយកសេចក្តីក្រាបបង្គំទូលព្រះចៅ

ហៀនតេឲ្យទ្រង់ជ្រាបថា យើងនឹងលើកកងទ័ពមកព័ទ្ធចាប់លីឈុយ គុយគីសម្លាប់ចេញ ឯអ្នកទាំង ៣ ក៏ត្រូវនៅគិតការខាងកងឲ្យមាំមួនចុះ" ។

ឯម៉ាហ៊ូ តុងសៀវ ឡៅឈៀ លុះបានដឹងសេចក្ដីកងសំបុត្រនោះហើយ ទើបចូលទៅក្រាបបង្គំទូលព្រះចៅហៀនតេ ។ ទ្រង់មានព្រះរាជហឫទ័យសោមនស្សណាស់ ទ្រង់ត្រាស់ឲ្យយកក្រដាសទឹកខ្មៅមក ទ្រង់ព្រះសុកអក្សរជាសេចក្ដីថា "ដែលម៉ាថេងនឹងហាន់ស៊ុយគិតការដូច្នោះ យើងត្រេកអរណាស់ បើបានសម្រេចដូចសេចក្ដីប្រាថ្នាហើយ យើងនឹងតាំងឲ្យធ្វើជានាហ្មឺនធំតទៅ" ស្រេចហើយក៏ប្រគល់ឲ្យបំរើម៉ាថេងហាន់ស៊ុយកាន់ត្រឡប់មកវិញ ។

ម៉ាថេង ហាន់ស៊ុយ ទទួលសុកអក្សរលាមើលឃើញព្រះហត្ថលេខា ក៏មានសេចក្ដីត្រេកអរណាស់ ទើបរៀបចាត់ចែងកេណ្ឌទាហានទាំង ២ ខែត្របានប្រហែល ១១-១២ ម៉ឺន លើកទៅដល់កណ្ដាលផ្លូវហើយឲ្យទាហានស្រែកប្រកាសប្រាប់បណ្ដារាស្ត្រគ្រប់ភូមិស្រុកថា យើងលើកទ័ពមកនេះ ដើម្បីនឹងធ្វើការកំចាត់សត្រូវរាជសម្បត្តិចេញ ។

បំរើសេះបានឮច្បាស់ ក៏នាំសេចក្ដីនោះទៅប្រាប់គុយគី ។ ឲ្យរកគៀវបេហួនគៀវមកប្រឹក្សាថា ម៉ាថេង ហាន់ស៊ុយលើកទ័ពមកនេះយើងនឹងគិតប្រការណា ។ កាសៀងទីប្រឹក្សាតបថា ម៉ាថេងហាន់ស៊ុយលើកទ័ពមកនេះអស់រយៈផ្លូវឆ្ងាយដាច់ស្រយាលណាស់ យើងត្រូវរក្សានាទី

ទុកឲ្យគេលើកឡោមព័ទ្ធដល់ជើងកំពែងចុះ បើកាលណាខាងគេដាច់ស្បៀងអាហារហើយ សិមយើងលើកទាហានចេញទៅវាយទំលាយកង-ទ័ព យើងនឹងចាប់ម៉ាថេងនឹងហាន់ស៊ុយបានដោយងាយ ៗ លីបងនឹងអងហងឆ្លើយថា ដែលកាសៀងថានោះខ្ញុំមិនយល់ផងសោះ ខ្ញុំសុំទាហានមួយម៉ឺនលើកទៅចាប់ម៉ាថេងនឹងហាន់ស៊ុយ កាត់យកក្បាលជូនលោកឲ្យបាន ៗ កាសៀងតបថា នឹងឲ្យលីបងអងហងលើកទ័ពទៅនោះមុខជានឹងចាញ់ប្រៀបគេជាប្រាកដ ៗ លីបងអងហងឆ្លើយថា បើយើងចេញទៅហើយមិនបានក្បាលម៉ាថេងនឹងហាន់ស៊ុយមកជូនទេ អ្នកចូរកាត់ក្បាលយើងជាចំនួសចុះ បើយើងបានក្បាលនាយទ័ពទាំងពីរចូលមក អ្នកចូលកាត់ក្បាលអ្នកឲ្យយើងវិញ ៗ

កាសៀងជំរាបទៅលីឈុយនឹងគុយគីថា បើលីបងនឹងអងហងសុំយកអាសាចេញទៅច្បាំងក៏ឲ្យទៅចុះ តែភ្នំបៀវប៉ិតនោះ ចម្ងាយផ្លូវពីស្រុកក្រុងនេះប្រហែល ២០០០ សិន ពីខាងលិចមានតែផ្លូវបំពោះដើរតាមច្រកភ្នំចង្អៀតណាស់ បើដូច្នេះសុំឲ្យគៀវបេនឹងហួនគៀវលើកទាហានទៅបង្កប់នៅជំបន់នោះឲ្យច្រើន បើកាលណាលីបងនឹងអងហងចាញ់ប្រៀបគេថយមកប្រការម្ដេចក៏នឹងបានជួយគ្នា ៗ

លីឈុយ គុយគីឆ្លើយថា "ដែលនឹងឲ្យគៀវបេហួនគៀវលើកទាហានទៅតាំងនៅច្រកភ្នំនោះយើងមិនយល់ព្រមផងទេ," ហើយប្រ-

គល់ទាហានមួយម៉ឺនប្រាំពាន់ឲ្យលីបងនឹងអងហាង លើកចេញទៅតាមផ្លូវប្រហែល ២០០ ស៊ិន (៨០ គ.ម.) ទទួលជួបកងទ័ពម៉ាថេងនឹងហានស៊ុយលើកមកប្រទល់គ្នានៅទីនោះ ។ លុះព្រឹកឡើងនាយទ័ពទាំងសងខាងបញ្ចេញទាហានមកខាងក្រៅបន្ទាយ, ម៉ាថេងនឹងហានស៊ុយស្រែកថា អាលីបង អាអងហាង ជាសត្រូវរាជសម្បត្តិ នរណានឹងទទួលអាសាចេញទៅចាប់វាឲ្យយើងបាន ។ ម៉ាឈៀវជាកូនម៉ាថេងអាយុ ១៨ ឆ្នាំ សម្បុរមុខដូចពណ៌ថ្មយុក កិរិយារហ័សរហួនកាន់ទួនជិះសេះបំពោរទាហានចេញទៅទទួលយកអាសា ។ អងហាងឃើញម៉ាឈៀវនៅក្មេងណាស់ ក៏មើលងាយមិនសូវប្រយ័ត្ន ឡើងសេះកាំដាវចេញមកតយុទ្ធនឹងម៉ាឈៀវបាន ៥ ស្ទៀត, ម៉ាឈៀវយកទួនចាក់អងហាងធ្លាក់ពីលើសេះស្លាប់ហើយម៉ាឈៀវកន្ត្រាក់សេះប្រុងនឹងត្រឡប់មកវិញ, លីបងខឹងណាស់ក៏បរសេះកាំដាវដេញកាប់ម៉ាឈៀវពីក្រោយ, ម៉ាឈៀវក្រឡេកមើលធ្វើជាមិនឃើញ, ម៉ាថេងស្រែកប្រាប់ម៉ាឈៀវថា "សត្រូវតាមពីក្រោយមកជិតហើយឲ្យប្រយ័ត្ន" លីបងដេញជិតជិតនឹងទាន់យកដាវកាប់ម៉ាឈៀវៗរងជាប់ត្រឡប់ញាក់សេះបែរទៅវិញ លោតចាប់លីបងបាន ក៏នាំមកជូនម៉ាថេងជាបិតា បណ្ដាទាហានម៉ាថេងទាំងប៉ុន្មានបានចំណាប់ក៏ព្រួតគ្នាដេញកាប់ទាហានលីបងស្លាប់ជាច្រើន ។ ម៉ាថេងនឹងហានស៊ុយ ក៏លើកទាហានចូលទៅតាំងបន្ទាយនៅជិតកំពែងស្រុក

តៀងហាន់ ហើយឲ្យយកលីបង់ទៅសម្លាប់កាត់ក្បាលដោតទុកនៅមុខបន្ទាយ ។

មានបំរើសេះចូលទៅប្រាប់លីឈុយ គុយគីថា លីបង់នឹងអង់ហាងបាក់ដ័យក្បួយទាំង ២ នាក់ទៅហើយ ។ លីឈុយគុយគីប្រឹក្សាគ្នាថា ការសៀងថានោះត្រូវណាស់ យើងមិនធ្វើតាមពាក្យគាត់បានជាខូចខាតទាហានអស់ទៅដូច្នេះ ។ តាំងពីនោះមក លីឈុយគុយគីក៏សរសើរជឿស្រឡាញ់កាសៀងទុកជាទីប្រឹក្សា ហើយឲ្យចាត់ចែងចែងទាហានកបន្ទាយរាយរបាំងតាំងជីកគូលើកកំពែងយ៉ាងមាំមួន រួចកេណ្ឌទាហានឲ្យឡើងលើសែនក្រវេនចាំគយល្បាតប្រយ័ត្នការគ្រប់បន្ទាយ ។

ឯម៉ាថេងនឹងហាន់ស៊ុយលើកទាហានទៅសន្ធប់ ផ្ទាប់ជើងកំពែងស្រុកជុំបរិវេណប្រហែល ២ ខែ ។ ឯទាហានកងកងទ័ពនោះក៏ដាច់ស្បៀងអាហារជាយូរថ្ងៃ មានសេចក្ដីស្រេកឃ្លានពន់ប្រមាណណាស់ ។ ម៉ាថេងនឹងហាន់ស៊ុយ ឃើញទាហានរបស់ខ្លួនដាច់ស្បៀងអាហារដូច្នោះ ក៏ប្រឹក្សាគ្នានឹងឲ្យលើកកងទ័ពត្រឡប់ទៅវិញ នៅកំពុងជជែកគ្នា ។

ខណៈនោះមានបំរើស្និទ្ធរបស់ម៉ាហ៊្វូ លបនាំពត៌មានទៅប្រាប់លីឈុយគុយគីថា ម៉ាហ៊្វូជានាយខ្ញុំបាទគប់គិតនឹងគុងសៀវឡៀឈៀទទួលធ្វើជាកលសឹក ទើបម៉ាថេងលើកពលមកធ្វើស្គ្រាម ។ លីឈុយគុយគីឮដូច្នោះខឹងណាស់ ទើបឲ្យទាហានទៅចាប់ម៉ាហ៊្វូ គុងសៀវនឹង

ទៀតឡើយ ហើយនឹងកិរិយាបុត្រញាតិសន្តាន បានហើយឲ្យនាំយកទៅសម្លាប់ទាំងអស់ កាត់ក្បាលមេទាំង ៣ នាក់ដោតផ្កាលទុកនៅមុខ សែនឲ្យស្រុកត្រូវក្រះឡកឃើញ ។ មាន់ថេងនឹងហាន់ស៊ុយឃើញដូច្នោះក៏ប្រឹក្សាគ្នាថា "កលសឹកកូនស្រុកក្រុងបែកខ្ចាត់ខ្ចាយហើយ ទាហានកូនកងទ័ពក៏ដាច់ស្បៀងអាហារទៀត បើនឹងឡោមតុំទ្រូកងទុកដូច្នេះ មុខជានឹងខូចខាតទាហានច្រើនណាស់" លុះប្រឹក្សាព្រមព្រៀងគ្នាហើយ ទើបលើកទ័ពត្រឡប់ទៅវិញ ។

លីឈុយ គុយគ៏ឃើញដូច្នោះ ទើបឲ្យតៀវចេលើកទាហានទៅតាមមាន់ថេង ១ កង ឲ្យហួនតៀវលើកទាហានទៅតាមហាន់ស៊ុយ ១ កង លុះទៅដល់កំកាន់ចេង ហាន់ស៊ុយក្រឡេកមកឃើញហួនតៀវក៏ស្រែកថា អ្នកនឹងយើងជាមនុស្សនៅស្រុកជាមួយគ្នាមកពីតូច ហេតុម្តេចក៏ក្តួចសេចក្តីមេត្រីសោះ ត្រឡប់ជាមកធ្វើអន្តរាយដល់យើង ។ ហួនតៀវតបថា សត្វថៃនេះ រាជការកូនស្រុកក្រុងជាកម្មសិទ្ធិលើលីឈុយគុយគី បានប្រើយើងលើកទាហានមកតាមអ្នកគ្រានេះ ប្រយោជន៍នឹងប្រហារជីវិតអ្នក ដែលយើងនឹងយល់មុខអ្នកជាអ្នកនោះមិនបានទេ ។ ហាន់ស៊ុយតបថា យើងលើកទាហានមកធ្វើសង្គ្រាមគ្រានេះ ក៏ព្រោះតែនឹងជួយទំនុកបំរុងផែនដីឲ្យបានសេចក្តីសុខ បើអ្នកមិនគិតដល់យើងក៏រាហាទៅចុះ តែត្រូវគិតដល់ព្រះហៀនទេះតជាម្ចាស់ផែនដី ព្រោះអ្នកជាមន្ត្រីស្តេច

ដូចគ្នា ៗ ហ្លួនតៀវបានឮហាន់ស៊ុយនិយាយដូច្នោះ ក៏នឹកឃើញសេចក្ដីកតញ្ញូឡើង ក្នុងចិត្តនឹកអាណិតហាន់ស៊ុយ ទើបឲ្យទាហានបង្អង់ឈប់នៅទីនោះ; ឯហាន់ស៊ុយក៏ស្រុតលើកទាហានទៅស្រុកប៉េងជីវ ៗ.

ឯតៀវចេដែលលើកទាហានទៅតាមម៉ាថេងនោះ លុះមិនទាន់ហើយក៏ត្រឡប់ទាហានមកតាំងនៅជាមួយនឹងហ្លួនតៀវ ៗ ឯលីទៀតដែលជាក្មួយលីឈុយនៅជាមួយនឹងកងទ័ពហ្លួនតៀវ លុះឃើញហ្លួនតៀវមិនបានចាប់ហាន់ស៊ុយដូច្នោះ ក៏នាំយកសេចក្ដីនោះចូលទៅប្រាប់លីឈុយជាមា ៗ លីឈុយឮហើយក៏នឹកខឹងណាស់ គិតនឹងប្រើទាហានឲ្យទៅចាប់ហ្លួនតៀវ ៗ កាសៀងជីងដូច្នោះ ក៏ឃាត់លីឈុយថាឥឡូវស្រុកទេសកំពុងវឹកវរចលាចល ដែលនឹងប្រើកលទៅចាប់ហ្លួនតៀវនោះ ឃើញថាហ្លួនតៀវមិនមែនព្រមឲ្យចាប់ដោយងាយទេ មុខជានឹងកើតសឹកសាមសង្គ្រាមជ័យនឹងគ្នាមិនខាន, សុំឲ្យចាត់មនុស្សចេញទៅប្រាប់ហ្លួនតៀវ តៀវចេដោយល្អវិញថា ដែលលើកទៅតាមម៉ាថេងហាន់ស៊ុយមិនទាន់នោះក៏រាហើទៅចុះ ឥឡូវត្រូវយើងរៀបលៀងអាហារអញ្ជើញនាហ្មឺនទាំងអស់មកបរិភោគជាសប្បាយ ហើយឲ្យបំរើទៅហៅហ្លួនតៀវតៀវចេចូលមកបរិភោគអាហារជាមួយ កាលបើចូលមកហើយសឹមយើងឲ្យចាប់ហ្លួនតៀវសម្លាប់ចេញ កាលបើធ្វើដូច្នោះទើបមិនមានភ្ញាក់ផ្អើលច្រូលច្របល់ ៗ លីឈុយបានស្ដាប់យល់ឃើញថាស្រួល

ហើយក៏រៀបចំអាហារគោជនបាត់មនុស្សឲ្យចេញទៅហៅហ្លួនតៀវ និង តៀវចេចូលមកបរិភោគអាហារ ។ ឯហ្លួនតៀវនិងតៀវចេមិនបានដឹង គលឧបាយនោះ ក៏លើកទាហានត្រឡប់ចូលមកកាន់ក្រុងវិញ ហើយ ចូលទៅបរិភោគអាហារជាមួយនឹងលីឈុយគុយគី ។ កាលកំពុងផឹកស្រា លីឈុយនិយាយនឹងហ្លួនតៀវថា យើងឲ្យលើកទាហានទៅតាមចាប់ ហាន់ស៊ុយ ហេតុម្ដេចខ្លួនមិនធ្វើតាមពាក្យយើងបង្គាប់ត្រឡប់បែរបិត្តទៅ អាណិតហាន់ស៊ុយវិញ ខ្លួននឹងគិតគំនិតអាក្រក់ស្អប់យើងឬ?។ ហ្លួនតៀវ ឮដូច្នោះ ក័យណាស់មិនទាន់ឆ្លើយថាប្រការម្ដេច ពេជ្ឈឃាដស្ទុះទៅ ចោមចាប់ខ្លួនហ្លួនតៀវយកទៅមួយរំពេច ហើយកាត់យកក្បាលមកជូន លីឈុយមើល ។

តៀវចេឃើញដូច្នោះ មិនដឹងជាមានហេតុអ្វី ក័យណាស់ក៏ឱនមុខ ក្រាបលើគែមតុ ។ លីឈុយក៏ទៅគ្រាហ៍លើកឡើងហើយប្រាប់ថា ហ្លួនតៀវបែបិត្តក្បត់យើង បែរទៅចូលគំនិតគ្នានឹងហាន់ស៊ុយគិតប្រ- ទូសរ៉ាយយើងវិញ បានជាយើងធ្វើដូច្នេះ ឯចំណែកខ្លួនអ្នកមិនមានរឿង ខុសពីអ្វីទេកុំឲ្យក័យបារម្ភ ” ថាហើយក៏ប្រគល់ពួកពលទាហាន ដែល ហ្លួនតៀវនាំមកនោះឲ្យទៅតៀវចេទាំងអស់ ហើយចាត់ប្រើតៀវចេឲ្យ លើកពលទៅរក្សាស្រុកហងឡុងដូចដើម ។

ក្នុងសម័យនោះ មនុស្សម្នាបណ្ដាដែលមាននៅក្នុងក្រុងគៀនហាន់ ក៏កាន់តែមានសេចក្ដីកោតញញើតខ្លាចលីឈុយគុយគី ។ ឯការសៀងនោះក៏ចេះតែនិយាយពន្យល់ លីឈុយ គុយគី ឲ្យយកចិត្តអាណិតស្រឡាញ់នាហ្មឺនទីងកស្រុកក្នុងក្រុងឲ្យផ្លុងចិត្តគិតរាប់អានមកវិញ, បណ្ដានាហ្មឺនទីងកស្រុកសឹងនៅក្រោមអំណាចលីឈុយ គុយគី ទាំងអស់ ។

គ្រានោះ មានសំបុត្រមកពីស្រុកសៀងជីវថា មានពួកចោរជួតក្បាលលឿងប្រមាណ ៣០ ឬ ៤០ ម៉ឺន ត្រាច់ផ្ដាត់ធ្វើទុក្ខបុកម្នេញអាណាប្រជានុរាស្ត្រជាចលាចល ។ លីឈុយ គុយគី បានឃើញសំបុត្រហើយក៏ប្រឹក្សានឹងនាហ្មឺនទាំងពួងថា ដែលកើតចោរអន្តរាយគ្រប់ខែត្រខណ្ឌដូច្នេះ យើងត្រូវគិតយ៉ាងណាទើបនឹងកម្ចាបពួកចោរទាំងនោះបាន ។ ដូហ៊ីឆ្លើយថា ដែលកើតចោរកម្មប្រជុំនៅក្នុងស្រុកសៀងជីវនោះ ខ្ញុំបាទឃើញតែចូឆូ ១ នាក់ដែលមានថ្វីដៃខ្លាំងពូកែ បើនឹងចាត់ឲ្យទៅប្រាបប្រាមពួកអាចោរ ដែលនៅខាងទិសឯកើតនោះ មុខជានឹងបានសម្រេចដូចបំណង ។ លីឈុយ គុយគី សួរតបទៅវិញថា ចូឆូនោះសព្វថ្ងៃនៅឯណា ? ។ ដូហ៊ីឆ្លើយថា ចូឆូនោះបានមកធ្វើទ័ពជាមួយនឹងអួនសៀវកាលគ្រាចម្បាំងនឹងតាំងតុ: ឥឡូវត្រឡប់ទៅនៅស្រុកបុងគុន មានសេនាទាហានជាច្រើន បើលោកត្រូវការសុំឲ្យមានសំបុត្រព្រះកម្មាស់ព្រះចៅហៀនតេចេញទៅ បង្គាប់ឲ្យចូឆូលើកកងទ័ពទៅបង្ក្រាប

ពួកអាចោរក្នុងស្រុកសៀងដីវចុះ ។ លីឈុយ គុយគី យល់ឃើញថាត្រូវ ក៏តែងសំបុត្រព្រះតម្រាស់ ២ ច្បាប់ ១ ច្បាប់ប្រាប់ទៅប៉ៅស៊ុនចៅហ្វាយស្រុកប៉ាក់ប៉េង, សំបុត្រ ១ ច្បាប់ទៀតប្រាប់ទៅចូចូ ឲ្យលើកទាហានរួមគ្នាទៅបង្ក្រាបពួកចោរក្នុងដែនស្រុកសៀងដីវ ។

ឯប៉ៅស៊ុន ដល់បានទទួលព្រះតម្រាស់ហើយ ក៏ចាត់ចែងកេណ្ឌទាហានលើកទៅរកចូចូ ទទួលសំបុត្រព្រះតម្រាស់ មកមើលដឹងហើយ មានសេចក្ដីត្រេកអរណាស់ តាំងតែកេណ្ឌកងសេនាទាហានបានជាច្រើន ហើយនាំប៉ៅស៊ុនលើកពលទៅតំបន់ស៊ីវស៊ុនក្នុងដែនស្រុកសៀងដីវ បានចួបប្រទះពួកចោរជួតក្បាលលឿង ១ ពួកតាំងផ្ដុំគ្នាជាច្រើន ប៉ៅស៊ុនសុំយកអាសាចេញទៅតតាំងច្បាំងនឹងពួកចោរ ។ ក៏តទល់គ្នាជាប្រឹងប្រាញណាស់; ទាហានចោរលើកគ្នាចោមព័ទ្ធសម្លាប់ប៉ៅស៊ុនស្លាប់ក្នុងទីនោះ ។

ចូចូឃើញប៉ៅស៊ុនស្លាប់នឹកខឹងណាស់ លើកទាហានចូលទៅកាប់សម្លាប់ពួកចោរស្លាប់ជាច្រើន ហើយដេញទាហានទន្ទ្រានចូលទៅទៀតដល់ស្រុកបេប៉ាក់ស្លាក់ចាប់បានពួកចោរ ។ ត្រឡប់ចុះចូលមូលមកនៅនឹងចូចូវិញប្រហែល ៤ · ៥ ម៉ឺននាក់ ហើយចូចូឲ្យពួកចោរឈ្លើយនោះជាកងមុខ លើកទៅសង្កត់សង្កិនពួកចោរគ្រប់តំបន់ ។ ចូចូលើកទ័ពទៅបង្ក្រាបពួកចោរយូរប្រមាណ ២ ខែ, ពួកចោរក៏ចុះចូលមកជាស្ម័គ្របក្សពួកចូចូ ទាំងចាស់ទាំងថ្មីបានប្រហែល ៣០ ម៉ឺន ។ (មានត)

# ព្រះរាជពង្សាវតារប្រទេសកម្ពុជា

## ភាគទី ២

### សម័យឯករាជ

## អ្នកឧកញ៉ាទេពពិទូរ ឈឹម - ក្រសេម រៀបរៀង

(តទៅ)

ព្រះបាទយសោវរ្ម័ន បានស្តេចចេញតយុទ្ធទល់នឹងបច្ចាមិត្រពេញសមត្ថភាព, តែពុំឈ្នះ សត្រូវបានធ្វើគត់ព្រះអង្គបង់ ហើយឡើងគ្រងរាជបល្ល័ង្ក ៗ ឯព្រះបរមសពនៃព្រះបាទយសោវរ្ម័ន គេមិនបានថ្វាយព្រះនាមព្រះកិត្តិយសតាមរាជប្រវេណីទេ ព្រោះព្រះរាជាថ្មីនោះជាគូសត្រូវទៅហើយ មិនត្រូវការនឹងថ្វាយកិត្តិយសដល់គូសត្រូវរបស់ខ្លួន ៗ

**រជ្ជកាលនៃព្រះត្រីភុវនាទិត្យ =** ព្រះត្រីភុវនាទិត្យនេះ គឺជាមន្ត្រីធំម្នាក់ ដែលបានក្បត់ព្រះបាទយសោវរ្ម័ន (ទី ២) ដូចបានពោលហើយ មន្ត្រីនេះប្រហែលជាមានសមត្ថភាពគ្រាន់បើ ទើបអាចផ្តួលព្រះបាទយសោវរ្ម័នបាន ៗ កាលរំលាងបានហើយ ក៏ឡើងគ្រងរាជបល្ល័ង្ក មានព្រះនាមថា:

### ព្រះបាទត្រីភុវនាទិត្យ

**ព. ស. ១៧០៨ - ១៧២០ គ. ស. ១១៦៥ - ១១៧៧**

ទ្រង់មានព្រះអគ្គមហេសីព្រះនាមដូចម្តេច នឹង មានព្រះរាជឱរស ព្រះរាជធីតាប៉ុន្មានទេ មិនប្រាកដក្នុងប្រវត្តិសាស្ត្រនេះ ៗ

**និយាយពីព្រះជ័យវរ្ម័ន** = ឯព្រះជ័យវរ្ម័ន ដែលទ្រង់រង់ចាំឱកាសនៅក្រុងវិជ័យមកជាយូរដូចមានពោលហើយ, កាលទ្រង់ជ្រាបរឿងមន្ត្រីទុរយសក្បត់ព្រះបាទយសោវរ្ម័ន ក៏ស្តេចម្មីមា យាងត្រឡប់មកព្រះនគរវិញ ។ ប្រាកដតាមសិលាចារិកនៅប្រាសាទវិមានអាកាសថា "ស្តេចយាងមកដើម្បីជួយស្រោចស្រង់ព្រះបាទយសោវរ្ម័នដែលត្រូវក្បត់" ។

ក្នុងខនេះ តាមយោបល់ ១ ថា យើងនឹងយល់ថាស្តេចមកដើម្បីស្រោចស្រង់ព្រះបាទយសោវរ្ម័នមែន តាមសិលាចារិកនោះក៏បាន ឬនឹងយល់ថា ព្រះអង្គយាងមកដើម្បីទាមទាររាជសម្បត្តិក៏បាន ព្រោះទ្រង់បានរង់ចាំឱកាសបែបនេះមកយូរហើយ, តែកាលស្តេចយាងមកដល់ព្រះនគរ ក៏ស្រាប់តែឃើញសត្រូវ គឺព្រះត្រីភវនាទិត្យនៅលើរាជបល្ល័ង្កទៅហើយ ទ្រង់ក៏គៀងគាក់ព្រះហឫទ័យ ........ តែក្នុងទីបំផុតទ្រង់ក៏បណ្ដោះបណ្ដាលព្រះហឫទ័យថា ត្រូវតែអត់ធ្មត់ទៅសិន ចាំរកឱកាសជាថ្មីទៅទៀត ។

ក្នុងគ្រានោះ ព្រះជ័យវរ្ម័នបានជួបនឹងព្រះនាងជ័យរាជទេវី ជាព្រះអគ្គជាយានឹងព្រះរាជឱរសរបស់ព្រះអង្គ ដែលទ្រង់ចាកចោលទៅយូរហើយ ។ វេលានោះព្រះនាងជ័យរាជទេវីបានទូលញុះញង់ព្រះរាជស្វាមីឲ្យរំលំរាជសត្រូវចេញអំពីរាជបល្ល័ង្ក ។ ទ្រង់ទូលថា នឹងធ្វើតាមយ៉ាងនោះ ក្នុងពេលដែលបានឱកាសស្រួល ។ អំពីនោះមកព្រះ

ជយវរ្ម័ន ទ្រង់គង់នៅក្នុងប្រទេសកម្ពុជា ជាមួយព្រះអគ្គជាយា តែគង់នៅដោយស្ងាត់ស្ងៀម រង់ចាំបានឱកាសល្អតមក ។

**និយាយអំពីប្រទេសចាម្ប៉ា =** ក្នុងពេលដែលប្រទេសកម្ពុជាកំពុងតែបះបោរដូចមានពោលមកហើយនោះ ខាងប្រទេសចម្ប៉ា ក៏មានការបះបោរដែរ គឺក្នុងរវាងឆ្នាំ គ.ស. ១១៦៦ - ១១៦៧ មានបុរស ១ នាក់ដែលគេមិនដឹងជាមកពីណា បានមកបង្កការណ៍ក្បត់ដណ្តើមយករាជសម្បត្តិ នៃក្រុងចម្ប៉ាបានសម្រេចហើយ ឡើងសោយរាជ្យប្រកដព្រះនាមថា "ព្រះបាទស្រីជយឥន្ទ្រវរ្ម័ន" ទំនងបែបយ៉ាងព្រះត្រី-ភវនាទិត្យ ។ ក្រោយដែលឡើងគ្រងរាជសម្បត្តិហើយ គឺក្នុងឆ្នាំ ព.ស. ១៧១៣ គ.ស. ១១៧០ ស្តេចនេះបានចាត់បញ្ជូនរាជទូត ឲ្យនាំរាជ-បណ្ណាការទៅថ្វាយក្សត្រយួន សុំចងសម្ពន្ធមេត្រីភាព, ស្តេចយួនក៏បានទទួលជាសម្ពន្ធមេត្រីផង ។ ការដែលសុំចងសម្ពន្ធមេត្រីភាពនឹងស្តេចយួនជាមុនយ៉ាងនេះ ក៏ដោយបំណងនឹងបិទផ្លូវកុំឲ្យយួនមកជួយខ្មែរ ក្នុងពេលដែលខ្លួនលើកទ័ពមកវាយ ប្រទេសខ្មែរក្នុងថ្ងៃ១ ។ ស្តេចស្រីជយ-ឥន្ទ្រវរ្ម័ននេះ ជាអ្នកអំនួតអួតឫទ្ធិក្អេងក្អាងហាក់ដូចជាក្រុងពពណ៌ ។

## សង្គ្រាមចាម្ប៉ាគ្រាទី ៤

ក្រោយដែលចងសម្ពន្ធមេត្រីភាពនឹងយួន ១ ឆ្នាំ គឺក្នុងឆ្នាំ ព.ស. ១៧១៤ គ.ស. ១១៧១ ព្រះស្រីជយឥន្ទ្រវរ្ម័នបានលើកទ័ព ដោយផ្លូវ

ដើរគោកមកវាយប្រទេសកម្ពុជា ដែលជាប្រទេសល្អបំផុត ហាក់ដូចជាឋានសួគ៌ ប៉ុន្តែគួបផ្សំ គឺព្រះបាទត្រៃកវនាទិត្យក៏មានឫទ្ធិខ្លាំងក្លាណាស់ដែរ ព្រះស្រីជយវរ្ម័ននៅវាយមិនបែក ក៏លើកទ័ពត្រឡប់ទៅវិញ ទាំងសេចក្ដីឈឺចិត្តក្ដៅក្រហាយ ទ្រង់ ។ អំពីនោះមកទ្រង់ក៏គិតរកឧបាយជានិច្ច ដើម្បីនឹងមកវាយប្រទេសកម្ពុជាជាថ្មីទៀត ។

# សង្គ្រាមចាម្បាគ្រាទី ៥

លុះដល់ឆ្នាំ ព. ស ១៧២០ ព្រះជយវរ្ម័ន គិតឃើញឧបាយថ្មី ក៏លើកទ័ពដោយផ្លូវជើងទឹក មកវាយប្រទេសកម្ពុជាម្ដងទៀត បានចិន ១ នាក់ដែលលង់សំពៅជាអ្នកនាំផ្លូវ ចូលមកតាមទន្លេមេគង្គ ហើយបត់ចូលទៅតាមទន្លេសាប ។ លុះដល់ហើយក៏លើកទ័ពឡើងគោក ចូលលុកព្រះមហានគរភ្លាម ក្នុងពេលដែលព្រះបាទត្រៃកវនាទិត្យមិនបានទ្រង់ប្រាបជាមុន ។ ការតស៊ូរបស់ព្រះបាទត្រៃកវនាទិត្យដោយទាហានចំនួនតិចនោះ មិនអាចទីងរាំងពួកសត្រូវបាន ពួកទាហានចាម្បាក៏លុកចូលក្នុងព្រះនគរបាន ព្រះបាទត្រៃកវនាទិត្យ ក៏នៅតែស៊ូទាល់តែក្សយព្រះជន្មក្នុងទីរណរង្គ ។ ទាហានចាម្បាបានវាយកំទេច និងដុតផ្ទះព្រះរាជនិវេសន៍ ហើយជញ្ជូនយកទ្រព្យសម្បត្តិទៅច្រើនជាអនេក ។

(មានត)

អនុសំវច្ឆរៈមហាសន្និបាត ទី ៧

## នៃមន្ត្រីសង្ឃ ក្នុងព្រះរាជអាណាចក្រ កម្ពុជា

របស់

## ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

(តចប់)

---

*ក្រោយពីរំលាយរដ្ឋសភានោះមក រដ្ឋាភិបាលបានបង្អាក់មិនបោះឆ្នោត ដោយសង្ឃឹមថាក្នុងអនាគតអសន្តិសុខនឹងបានអន់ថយទៅវិញ ៗ តែអសន្តិសុខនេះ គ្មានអន់ថយសោះរឹតតែមានកម្លាំងខ្លាំងឡើង នាំឲ្យមានសេចក្តីលំបាកឡើង ៗ ក្នុងការគិតបោះឆ្នោតនេះ ៗ*

*ឯប្រជាជាតិទាំងមូល នៅស្រឡាញ់លទ្ធិប្រជាធិបតេយ្យនៅឡើយ ខ្ញុំករុណានេះឯង ក៏ជាអ្នកធានាអះអាងលើច្បាប់រដ្ឋធម្មនុញ្ញ នឹងលើលទ្ធិប្រជាធិបតេយ្យនេះផង ៗ យើងទាំងអស់ ប្រាថ្នាចង់ឲ្យលទ្ធិប្រជាធិបតេយ្យគង់វង់នៅជាដរាប ហើយនឹងត្រូវឲ្យមានរដ្ឋសភា ជាតំណាងប្រជារាស្ត្រនៅអមរដ្ឋាភិបាលផង ៗ*

ការដោះស្រាយបញ្ហានេះ បើតាមយោបល់ខ្ញុំករុណា មានតែពីរផ្លូវទើបសម្រេចទៅកើត គឺគិតបោះឆ្នោតតាមពាក្យសុំរបស់គណៈបក្សខ្លះនិងបណ្តារាស្ត្រខ្លះ ឬក៏ត្រូវមហាក្សត្រិយ៍តាំងតំណាងរាស្ត្រចាស់ នៃរដ្ឋសភាលើកមុន ធ្វើជារដ្ឋសភា

## បណ្ដោះអាសន្នសិន ព្រោះតំណាងរាស្ត្រទាំងនោះ ទោះបីយ៉ាងណាក្ដីក៏ធ្លាប់មានបណ្ដារាស្ត្របោះឆ្នោតរើសរូបមកហើយដែរ ។

តែការដោះស្រាយទាំងពីរផ្លូវនេះ ជំនុំពុំបានដាច់ស្រេចសោះ, ខ្លះថា ការណ៍បោះឆ្នោតនាំឲ្យប្រទេសកើតមានចលាចលដល់នូវសេចក្ដីវិនាស, ខ្លះរំលឹកថា បើនឹងហៅរដ្ឋសភាចាស់ឲ្យមកប្រតិបត្តិការឡើងវិញឃើញថាខុសច្បាប់ ឬក៏នឹងនាំឲ្យកើតប្រតិបក្ខគ្នា ដោយការគំនុំស្អប់នឹងការសងសឹក ។

## អ្នកទាំងអស់ប្រាថ្នាចង់ឲ្យមានរដ្ឋសភា តែគ្មានអ្នកណាព្រមព្រៀងនឹងសម្រេច ឲ្យបានស្រេចគ្នាសោះ ។

ខ្ញុំករុណាមានសេចក្ដីសោមនស្សណាស់ បើសិនណាខេត្រក្រៅអាចនឹងបញ្ចេញយោបល់ឲ្យខ្ញុំករុណាបានខ្លះអំពីបំណងប្រជារាស្ត្រយើង ។

មុននឹងបញ្ចប់, ខ្ញុំករុណាយល់ឃើញថាគួរពិតពុទ្ធដីកាដោយសង្ខេបប្រគេនលោកគ្រូជ្រាប អំពីស្ថានការណ៍រវាងប្រទេសដែលស្ថានការណ៍នៃប្រទេសយើងតែងប្រស្រ័យទៅតាមស្ថានការណ៍ក្នុងសាកលលោក ។

អនាគតនៃពិភពលោកយើងជិតៗនេះគួរឲ្យព្រួយច្រើន ៗ មុននឹងអស់ព្រួយ អនាគតនោះប្រហែលជានឹងមានការលំបាកច្រើនលើសក្នុងសម័យបច្ចុប្បន្ននេះទៅទៀត ជាពិតប្រាកដ ។

– នៅជុំវិញយើងមានបម្លាំងជាយ៉ាងខ្លាំង ។ ពួកកាន់លទ្ធិរួមសម្ពាថ បញ្ចាំងនឹងអាម៉េរិកាំងនៅប្រទេសកូរ៉េ, បញ្ចាំងនឹងបារាំងក្នុងដែនឥណ្ឌូចិន នៅប្រទេសតុងកឹងជាដើម, បញ្ចាំងនឹងអង់គ្លេសនៅប្រទេសម៉ាឡាយូ ។ ពួកកាន់លទ្ធិរួមសម្ពាថបានចូលលុកលុយប្រទេសទីបេហើយ ។ បណ្ដាលឲ្យមានភ័យផ្ទាល់ចំពោះប្រទេសភូតង មានល្បឿនបែរមុខសំដៅមកប្រទេសភូមាផង ដែនឥណ្ឌូចិននឹងប្រទេសសៀមផង ។

នៅទ្វីបអឺរ៉ុប, ជាតិអាម៉េរិកាំងនឹងជាតិរុស្ស៊ីឃ្លាំគ្នាទៅវិញទៅមកនៅត្រៀមប្រឈមមុខគ្នាក្នុងប្រទេសអាល្លឺម៉ាញ ។

គេបារម្ភខ្លាចក្រែងមានបម្លាំងធំទី ៣ ក្នុងលោក ។ តែបម្លាំងមាននៅចុងបូព៌ាប្រទេសមកហើយ គឺមានខាងយើង ។

ការឃោសនាបញ្ចុះបញ្ចូលរបស់ពួកកាន់លទ្ធិរួមសម្ពាថ ផ្សាយដំណឹងថា លទ្ធិរួមសម្ពាថចូលមកស្រុកយើង ដើម្បីដោះយើងឲ្យរួចរបួត អំពីការនៅក្នុងចំណុះពួកបរស្ទិមប្រទេស ។ តែដោយពិចារណាសព្វគ្រប់ទៅ ខ្ញុំករុណាយល់ឃើញថា បើពួកកាន់លទ្ធិរួមសម្ពាថមានជ័យជំនះនៅស្រុកយើង នោះជាគុណប្រយោជន៍ចំពោះតែពួកវៀតមិញប៉ុណ្ណោះទេ ។ ឯពួកវៀតមិញដែលមកតាំងនៅក្នុងស្រុកយើងនេះទុកស្មើនឹងការបំបាត់មិនឲ្យមានខេមរអធិបតេយ្យ ។

មានតែជ័យជំនះអាមេរិកាំងនោះទេ ដែលនឹងគាំពារឯករាជ្យ ជាទីស្នេហារបស់យើងទាំងម៉្លេះនោះឲ្យនៅគង់វង់ ហើយចំរើនទៅមុខបាន ។ ប្រទេសអាមេរិកបានបង្ហាញឲ្យឃើញច្បាស់ជាងសព្វគ្រប់ហើយ អំពីឧត្តមគតិរបស់គេ ដែលការពារសេរីភាពនៃប្រជាជាតិនានា ។ ប្រទេសម៉ានិល នឹងប្រទេសទាំងប៉ុន្មាន នៅក្នុងទ្វីបអឺរ៉ុប ប៉ែកខាងបស្ចិមទិសនោះឯងសោត ក៏បានសេរីភាពមកដោយសារជ័យជំនះអាមេរិកាំងក្នុងសង្គ្រាមធំទី ២ ក្នុងលោកនោះដែរ ។

គឺដើម្បីនឹងការពារឯករាជ្យរបស់យើងនេះហើយ បានជាប្រទេសយើងត្រូវចងមិត្រមេត្រីជាមួយពួកលទ្ធិប្រជាធិបតេយ្យ នៅបស្ចិមទិស មានប្រទេសអាមេរិកាំងជាដើម ។ នៅក្នុងកំឡុងការលំបាកទាំងនេះ ខ្ញុំករុណា មានសេចក្ដីព្រួយបារម្ភនឹងវាសនានៃប្រជាជាតិយើងជាដរាប ។

មហិច្ឆតាតែមួយរបស់ខ្ញុំករុណា គឺប្រាថ្នាធ្វើឲ្យប្រជាជាតិយើងរួចផុតអំពីទុក្ខវេទនាទាំងអស់ ។ តែលោកគ្រូគ្រប់ព្រះអង្គជ្រាបស្រាប់ហើយថា កិច្ចការខ្ញុំករុណានេះពិបាកយ៉ាងណា ៗ បើខ្ញុំករុណានឹងសូមរំពឹងខ្លះផងលើលោកគ្រូនោះ គឺសូមលោកគ្រូដែលគង់នៅក្នុងអាណាខេត្ត គឺនៅជិតបណ្ដារាស្ត្រជាងខ្ញុំករុណានេះ សូមមានពុទ្ធដីកាទៅបណ្ដារាស្ត្រថា រដ្ឋាភិបាលនឹងមហាក្សត្រិយ៍មិនដែលភ្លេចបណ្ដារាស្ត្រមួយវេលាណាទេ ហើយសូមបណ្ដារាស្ត្រឲ្យអភ័យទោសអំពីការពិបាកទាំងប៉ុន្មាននោះ

ផង ដែលយើងបានខិតខំធ្វើបង់ឲ្យបណ្ដាក់ស្ដេចៀសវាងការពិបាកនេះ តែនៅចៀសវាងពុំទាន់រួច ។ ចំណែកខ្ញុំករុណា ៗ ក៏បានខិតខំបំរើជាតិមកតាមសមត្ថភាព ដែលខ្សត់ខ្សោយរបស់ខ្ញុំករុណា ។

នៅទីអវសាន ខ្ញុំករុណាសូមឧទ្ទិសដោយគោរព សូមឲ្យលោកគ្រូបានប្រកបដោយសេចក្ដីសុខសប្បាយគ្រប់ព្រះអង្គ ! និងសូមឲ្យព្រះពុទ្ធ-សាសនាបានប្រកបដោយកិត្តិគុណតរៀងទៅ ! ។

## សុន្ទរកថាឯកឧត្ដម សម - ញាណ

បន្ទាប់មក ឯកឧត្ដម សម - ញាណ រដ្ឋមន្ត្រីក្រសួងធម្មការនិងសិល្បការ បានថ្លែងសុន្ទរកថាពណ៌នាអំពីការចំរើននៃកិច្ចសិក្សាខាងព្រះពុទ្ធសាសនាដូចតទៅនេះ :-

សូមព្រះតេជះដ៏កល់លើត្បូង

សូមព្រះរាជទានក្រាបបង្គំទូលព្រះករុណាជាអម្ចាស់ជីវិត !

ទូលព្រះបង្គំជាខ្ញុំមានអំណរ ចំពោះល្អងធូលី ដែលស្ដេចយាងមកជាព្រះរាជាធិបតីនៃមហាសន្និបាតនេះ ។ ព្រមទាំងមានសោមនស្សចំពោះទ្រង់, ព្រះតេជព្រះគុណ លោក - អ្នកសប្បុរសទាំងឡាយ ដែលយាងអញ្ជើញមកក្រាបបង្គំគាល់ ជុំវិញព្រះអង្គនេះ ។

ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជានុញ្ញាត ដើម្បីប្រស្រ័យនឹងព្រះថេរានុត្ថេរទាំងឡាយ ដោយមានបំណងចង់ឲ្យបានជ្រាបដំណើរកិច្ចការ

ខ្លះ ខាងព្រះពុទ្ធសាសនាដែលក្រសួងធម្មការបានបំពេញ ក្រោមអធិបតីភាពនៃព្រះករុណាជាម្ចាស់ជីវិតលើត្បូង ។

សូមថ្វាយបង្គំសម្តេច នឹងព្រះថេរានុត្ថេរគ្រប់ព្រះអង្គ ជាមន្ត្រីសង្ឃគ្រប់តំណែងក្នុងព្រះរាជអាណាចក្រកម្ពុជា ។

ខ្ញុំព្រះករុណាមានចិត្តរីករាយយ៉ាងក្រៃលែង ចំពោះព្រះតេជព្រះគុណទាំងឡាយមានសម្តេចទាំង ៣ ព្រះអង្គជាប្រធាន ដែលបាននិមន្តមកកាន់ទីមហាសន្និបាតប្រចាំឆ្នាំទី ៧ នេះ ។

ទ្រង់! សម្តេច! ព្រះតេជព្រះគុណ! លោក-អ្នកជាពុទ្ធបរិស័ទទាំងឡាយ! ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំបាទជារដ្ឋមន្ត្រីក្រសួងធម្មការសូមឱនកាយគោរព ហើយសូមថ្លែងអំពីព្រះពុទ្ធសាសនាដែលមានដំណើរជឿនទៅកាន់សេចក្តីចំរើន ដោយអាស្រ័យច្បាប់លោកនឹងច្បាប់ធម៌ ដូចតទៅនេះ:—

ព្រះពុទ្ធសាសនា ដែលអាស្រ័យនឹងច្បាប់លោកនោះយ៉ាងណា?

អធិប្បាយថា: រដ្ឋធម្មនុញ្ញ មាត្រា ៨ ចែងថា: "សេរីភាពខាងជំនឿ ត្រូវបើកឲ្យមានដោយបរិបូណ៌ ។ សេរីភាពក្នុងការប្រតិបត្តិខាងផ្លូវសាសនាក៏ត្រូវបើកឲ្យមានដូច្នោះដែរ បើនឹងបទ្ទុយខ្លះតែត្រង់ណាដែលរៀរពុំបានដើម្បីកុំឲ្យខូចសេចក្តីសប់រៀបរយដល់មហាជន ។ ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ" ។ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំបាទ

សូមទុកាសអធិប្បាយអំពីចរិយាចិត្តនៃពពួកពុទ្ធបរិស័ទខ្លះប្រកាន់នូវជំនឿតាមលទ្ធិរបស់ខ្លួន ហើយអាងទៅលើរដ្ឋធម្មនុញ្ញដោយក់យសេចក្តីផ្ទុយខុសពីអត្ថរសនៃរដ្ឋធម្មនុញ្ញ ។

ក់យសេចក្តីផ្ទុយខុសនោះដូចម្តេច? ថាស្រេចហើយតែទឹកចិត្តជឿយ៉ាងណាក៏អាចធ្វើយ៉ាងនោះ ព្រោះអាងថារដ្ឋធម្មនុញ្ញបើកឲ្យជឿដោយបរិបូណ៌ហើយ ។

មកពីយល់ខុសដូច្នេះហើយដឹង? បានជាព្លថា មានពពួកពុទ្ធបរិស័ទ ខ្លះភេទជាបព្វជិត ខ្លះភេទជាគ្រហស្ថ ប្រព្រឹត្តឃ្លាងពីធម៌វិន័យរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ។

ឯអត្ថរសនៃរដ្ឋធម្មនុញ្ញមាត្រាខាងលើនេះបើក់យសេចក្តីឲ្យត្រឹមត្រូវដូចអធិប្បាយតទៅនេះ ៖

សេរីភាពខាងជំនឿ ត្រូវបើកឲ្យមានដោយបរិបូណ៌ គឺថាបុគ្គលមានសេរីភាពពេញទីខាងជំនឿ ។

ន័យមួយទៀតថា បុគ្គលគ្រប់រូបមិនថារូបណាចង់ជឿសាសនាណា ឬមិនជឿសាសនាណា បានតាមចិត្ត ។ ការដែលបើកឲ្យបានតាមចិត្តយ៉ាងនេះ ព្រោះគំនិតនៃរដ្ឋធម្មនុញ្ញ លោកការពារមិនឲ្យលោកអ្នកកាន់អំណាចបង្ខំចិត្តមនុស្សឲ្យចូលកាន់សាសនាណាមួយ តាមទំនើងចិត្តរបស់ខ្លួន ។ តែការនេះដូចជាគ្មាននៅប្រទេសខ្មែរទេ ។ ព្រោះជនជាតិខ្មែរ

មិនដែលបង្ខំជនណាឲ្យជឿតាមខ្លួនសោះឡើយ ។ ព្រោះព្រះពុទ្ធសាសនា តែងតែផ្សាយសេចក្តីសុចរិតនាំហេតុ-ផលមកពន្យល់ឲ្យមនុស្សស្តាប់បាន ហើយចុះចិត្តចូលកាន់តាមស្រ្គតិចិត្តឯង ។ តែមានសាសនាដទៃខ្លះមិនដូច្នេះទេ ដូចជាក្នុងប្រទេសពេមសម័យបុរាណមនុស្សដែលកាន់គ្រិស្ត-សាសនា ដំបូងត្រូវរងការធ្វើបាបដល់ទៅប្រហារជីវិត ។ ក្នុងប្រទេសអឺរ៉ុបអ្នកកាន់សាសនាប្រូតេស្តង់ ក៏ត្រូវរងការសង្កត់សង្កិនធ្វើបាបណាស់ដែរ គ្រាតែកើតចម្បាំងសាសនាឡើងពីសតវត្សទី ១៦-១៧ ។

ក្នុងប្រទេសឥណ្ឌាសម័យមុន មនុស្សដែលកាន់ព្រះពុទ្ធសាសនាត្រូវពួកហិណ្ឌូពួកមហាម៉ាត់សង្កត់សង្កិន តាំងពីឆ្នាំ ៧០០ ដរាបមកឆ្នាំ ៨០០ តទៅ ។ ការប្រើអំណាចសង្កត់សង្កិនលើជំនឿនោះ នាំឲ្យកើតក្តៅក្រហាយយ៉ាងច្រើន ។

លំដាប់តមក អារ្យធម៌បានចំរើនខ្ពស់ឡើង ៗ ទើបតាំងឲ្យមានសេរីភាព ។ សេរីភាពខាងសាសនាមានត្រាទុកក្នុងរដ្ឋធម្មនុញ្ញ នៃអារ្យ-ប្រទេសនានា ។ ការដែលមានចុះសេរីភាពខាងជំនឿ ក្នុងរដ្ឋធម្មនុញ្ញប្រទេសខ្មែរ ក៏ជាហេតុមួយសំដែងឲ្យឃើញថាជាតិយើងមិនមែនជាជាតិទាបថោកជាតិព្រៃផ្សៃទេ ។

សេចក្តីខាងលើនេះ បានដល់សេរីភាពខាងផ្លូវចិត្ត ចំពោះសាសនា ជាសេរីភាពដាច់ខាត គឺថារដ្ឋមិនអាចតាំងច្បាប់មកបំបាត់ ឬ

បន្ថយសេរីភាពនេះបានឡើយ ។ ប៉ុន្តែរដ្ឋអាចបន្ថយសេរីភាពនេះបានខ្លះ កាលបើការប្រតិបត្តិនោះ នាំឲ្យខូចសេចក្ដីស្ងប់រៀបរយ ដល់មហាជន ។ ប្រែសេចក្ដីថា កាលបើការប្រតិបត្តិសាសនាណាមួយ អាចនាំឲ្យមានចលាចលក្នុងប្រទេស ហើយប្រសិនណាជារដ្ឋ (រាជការ) យល់ថានឹងបណ្ដោយឲ្យប្រតិបត្តិទៅទៀតពុំបាន នោះរដ្ឋអាចហាមមិនឲ្យមានការប្រតិបត្តិសាសនានោះ ។

ឯកម្ពុជរដ្ឋប្រទេសយើងនេះ មានព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ បើលោកអ្នកទាំងឡាយណាមួយ ស្ម័គ្រចិត្តចូលកាន់ព្រះពុទ្ធ-សាសនា ត្រូវតែប្រតិបត្តិតាមធម៌វិន័យ ដែលសម្ដេចព្រះសង្ឃនាយកទាំងថេរសភា សង្ឃជាន់ខ្ពស់ទាំងពីរគណៈ បានផ្ទៀងផ្ទាត់តាមពុទ្ធបញ្ញត្តិ ព្រមព្រៀងជាឯកច្ឆន្ទទុកជាត្រឹមត្រូវហើយនោះ ត្រូវតែប្រតិបត្តិតាមជាដាច់ខាតខានមិនបាន ។ បើដូចជាសាសនិកជនទាំងឡាយណាមួយស្ម័គ្រចិត្តកាន់គ្រិស្តសាសនា ត្រូវតែប្រតិបត្តិតាមធម៌វិន័យ ដែលសម្ដេចព្រះសង្ឃ (បាប៉) បានពិនិត្យផ្ទៀងផ្ទាត់តាមច្បាប់បញ្ញត្តិរបស់ព្រះយេស៊ូ (ព្រះម្ចាស់សួគ៌) ទុកជាត្រឹមត្រូវហើយដាក់ឲ្យប្រតិបត្តិតាមយ៉ាងនោះ ។ ប៉ុន្តែសេរីភាពខាងជំនឿ បើកឲ្យជឿបានតាមចិត្ត ។ ប្រែថាជឿខាងព្រះពុទ្ធសាសនាក៏បាន ឬជឿខាងគ្រិស្តសាសនាក៏បាន ។ តែបើជឿខាងសាសនាណាមួយហើយ ត្រូវតែប្រតិបត្តិតាមធម៌វិន័យរបស់

សាសនានោះ មិនមែនឲ្យមានសេរីភាព ឲ្យប្រតិបត្តិខុសពីធម៌វិន័យរបស់សាសនានោះ បានតាមចិត្តឡើយ ។ ន័យយ៉ាងនេះហើយហៅថាច្បាប់លោក ។

អំពីច្បាប់ធម៌, ព្រះពុទ្ធសាសនាដែលអាស្រ័យនឹងច្បាប់ធម៌នោះ យ៉ាងណា?

មិនបាច់អធិប្បាយក្នុងទីនេះទៀតទេ ព្រោះពីល្ងាចម្សិលមិញសម្តេចព្រះសង្ឃនាយកវត្តបទុមវតី និងវត្តឧណ្ណាលោមមានព្រះពុទ្ធដីកាពន្យល់ជូនលម្អរួចហើយ ។ គ្រានេះគ្រាន់តែសូមបញ្ជាក់ តាមសាស្ត្រាច្បាប់ក្រមក្នុងវត្តមួយថា: "នរអ្នកណា ទោះយកអាត្មា ចូលសាសន៍ពុទ្ធរ័តន៍ ប្ដូរធ្វើឲ្យត្រង់ ដោយនូវបន្ទាត់ ហៅស្នងសម្បត្តិ យកផ្លូវនិព្វាន" ។

បន្ទាត់ពោលគឺព្រះវិន័យ (ច្បាប់), ព្រះវិន័យនេះ យើងទុកជាឫសគល់នៃព្រះពុទ្ធសាសនា ; អាស្រ័យហេតុនេះហើយបានជាព្រះបែយមហាក្សត្រិយ៍ ដ៏ទ្រង់នូវគុណាតិរេកឯកលើត្បូងនៃយើង ស្តេចចេញព្រះរាជក្រមលេខ ២១៤ ន. ស. ចុះថ្ងៃទី ២៥ ខែសីហា គ. ស. ១៩៥០ ស្តីអំពីការបង្កើតសាលារៀនធម្មវិន័យ គ្រប់វត្តអាកមទូទៅក្នុងព្រះរាជអាណាចក្រ ។

ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំបាទ មានអំណរយ៉ាងក្រៃលែងចំពោះព្រះរាជក្រមនោះ ។ អរផ្ទួនព្រោះឃើញសម្តេចព្រះសង្ឃនាយក

វត្តឧណ្ណាលោមកំពុងរៀបចំទីកន្លែងនៃសាលាធម្មវិន័យថែមទៀត ។ មុនដំណាច់ឆ្នាំ ១៩៥០ ត្រូវថា: សម្តេចអង្គនេះ បាននិមន្តទៅជាប្រធានក្នុងការប្រឡងធម្មវិន័យនៅវត្តពិកទូរង្សី ។ ព្រះតេជព្រះគុណព្រះមុនីកោសលមេគណខេត្តបាត់ដំបង នៅវត្តពោធិ៍វាលជាប្រធានក្នុងការប្រឡងធម្មវិន័យ ក្នុងខេត្តនេះ ។ ខេត្តសៀមរាប ខេត្តពោធិ៍សាត់ ខេត្តស្វាយរៀង ក៏សុទ្ធតែមានព្រះសង្ឃប្រឡងធម្មវិន័យ ដោយព្រះរាជប្រតិភូខេត្តនឹងលោកចៅហ្វាយខេត្តទាំងនោះ បានជួយទំនុកបំរុងជាផ្វការ ។ រួមព្រះសង្ឃដែលចូលប្រឡងធម្មវិន័យពល់កន្លែងខាងលើនេះចំនួន ២.៥០៧ អង្គ ។ ក្នុងចំនួននេះខេត្តបាត់ដំបងមាន ២.១០៩ អង្គ, ព្រោះតែព្រះសង្ឃនៅខេត្តបាត់ដំបងឧស្សាហ៍រៀនធម្មវិន័យច្រើនព្រះអង្គយ៉ាងនោះហើយដឹង? បានជាអធិករណ៍ឈ្មោះដណ្តើមលាភសក្ការ: ផ្សេងៗ គ្មានកើតឡើងក្នុងខេត្តនោះ ។ គួរឲ្យមានចិត្តត្រឹព្រួបហើយជ្រះថ្លាចំពោះព្រះសង្ឃដែលឧស្សាហ៍រៀនធម្មវិន័យ តាមព្រះរាជក្រមនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូងឥតអ្វីប្រៀបឡើយ ។ ព្រោះយល់ថាព្រះសង្ឃទាំងនោះហើយ ជាស្រែបុណ្យរបស់លោកអ្នកកាន់ព្រះពុទ្ធសាសនា ។

ម្យ៉ាងទៀត ព្រះប្រិយមហាក្សត្រិយ៍ព្រះអង្គជាពុទ្ធសាសនូបត្ថម្ភក: មានព្រះរាជហឫទ័យគោរពមានព្រះអធ្យាស្រ័យ ដ៏ធ្ងន់ទៅរកព្រះពុទ្ធ-

សាសនា ដូចព្រះករុណាគ្រប់ព្រះអង្គជ្រាបស្រាប់ហើយថា ទ្រង់មានប្រាថ្នាចង់ឲ្យព្រះពុទ្ធសាសនា មានពន្លឺរស្មីដ៏ភ្លឺរុងរឿង, ទើបទ្រង់ព្រះមេត្តាប្រោសប្រគេនសិទ្ធិដល់ព្រះសង្ឃ ក្នុងព្រះរាជអាណាចក្រឲ្យសិក្សាធម្មវិន័យព្រះពុទ្ធសាសនាដោយផាសុកភាព ដូចមានសេចក្ដីក្នុងព្រះរាជក្រមខាងលើស្រាប់ ។ មិនត្រឹមតែប៉ុណ្ណោះទ្រង់ប្រារព្ធដល់កិច្ចការក្នុងព្រះពុទ្ធសាសនា ចង់ឲ្យព្រះសង្ឃជាបណ្ឌិតមានសិទ្ធិសម្រេចកិច្ចការក្នុងព្រះពុទ្ធសាសនា កុំឲ្យកិច្ចការខាងព្រះពុទ្ធសាសនា ឋិតនៅក្នុងអំណាចនៃរាជការអាណាចក្រឡើយ, ទ្រង់សព្វព្រះរាជហឫទ័យថា រាជ-រដ្ឋាភិបាល មានព្រះអង្គជាប្រមុខនេះ គ្រាន់តែជួយឧបត្ថម្ភចំពោះកិច្ចការក្នុងព្រះពុទ្ធសាសនាដែលក្រសួងសង្ឃ បានចាត់ចែងហើយនោះឲ្យបានសម្រេចប៉ុណ្ណោះ ។ ព្រះរាជយោបល់យ៉ាងនេះ រាប់ថាជាព្រះករុណា-ធិគុណដ៏ថ្លៃថ្នូក្នុងប្រវត្តិសាស្ត្រ ។ ក្រសួងធម្មការនឹងចាត់ចែងឲ្យបានសម្រេចតាមព្រះរាជបំណង ក្នុងឆ្នាំ ១៩៥១ នេះពុំខាន ។

ទ្រង់ ! សម្ដេច ! ព្រះតេជៈព្រះគុណ ! លោកអ្នកជាពុទ្ធបរិស័ទទាំងឡាយ ! ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមអភ័យទោសមុនទៀតថា សេចក្ដីអធិប្បាយអំពីច្បាប់លោក ច្បាប់ធម៌ជាសង្ខេបប៉ុណ្ណោះ ដោយសុទ្ធចិត្តដ៏ល្អឥតមានលំអៀងថ្កោលទោសចំពោះលោកអ្នកទាំងឡាយណាមួយឡើយ ។ ក្រសួងធម្មការសង្ឃឹមថា អស់លោក

អ្នកជាពុទ្ធបរិស័ទ ទាំងបព្វជិតទាំងគ្រហស្ថ មុខជាប្រតិបត្តិតាមច្បាប់លោកច្បាប់ធម៌តទៅ ។ ក្រសួងធម្មការ នឹងយកចិត្តទុកដាក់ជួយឧបត្ថម្ភរាល់តែផ្លូវការ ដែលទាក់ទងចំពោះព្រះពុទ្ធសាសនាតទៅអនាគត ។

មុននឹងបញ្ចប់ ខ្ញុំព្រះករុណា សូមនូនកាយគោរព ដោយសោមនស្សចំពោះព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ មានសម្តេចទាំងបីព្រះអង្គជាប្រធានដែលបាននិមន្តមកកាន់ទីមហាសន្និបាតនេះ, សូមគុណានុភាពព្រះត្រៃរតនប្រសិទ្ធិពរ ចំពោះព្រះថេរានុត្ថេរៈទាំងឡាយមានសម្តេចជាប្រធានឲ្យបានប្រកបដោយសុខសួស្តី ក្នុងផ្លូវក្នុងផ្លូវព្រះពុទ្ធសាសនា ។

សូមថ្វាយព្រះរាជកុសល សូមជូនកុសល ចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រមទាំងអស់លោក-អ្នកសប្បុរសដែលបានបរិច្ចាគព្រះរាជទ្រព្យ អំណោយធនធានថ្វើអាគន្តុកទានចំពោះព្រះសង្ឃរាប់រយអង្គនាថ្ងៃសុភមង្គលនេះ ។ សូមកុសលរាសីអភិបាលរក្សាព្រះអង្គឲ្យបិតនៅក្នុងសិរីរាជសម្បត្តិយ៉ាងក្សេមក្សាន្ត ព្រមទាំងព្រះរាជវង្សានុវង្សដរាបដល់រយព្រះវស្សា ! ។ សូមផលានិសង្សនេះបង្ហូរទៅសេចក្តីសុខចំរើនគ្រប់ប្រការ ដល់លោក-អ្នករួមជាតិទាំងឡាយទូទៅក្នុងព្រះរាជអាណាចក្រ ! ។

ដោយអំណាចគុណានុភាពនៃព្រះរតនត្រៃ នឹងគុណានុភាពនៃបុណ្យកុសលនេះ សូមឲ្យអសន្តិសុខក្នុងប្រទេសយើងវិនាសបាត់ទៅ !

សូមឲ្យសន្តិសុខកើតមានក្នុងប្រទេសយើងកើតឡើង ! សូមឲ្យព្រះពុទ្ធសាសនាបានរុងរឿងចំរើនឡើង ! សូមព្រះករុណាជាអម្ចាស់ជីវិតលើត្បូង បានបំពេញនៅជាស្ពានក្នុងសិរីរាជសម្បត្តិ អស់កាលជាអង្វែង ! សូមរាជរដ្ឋាភិបាលនិងមន្ត្រីគ្រប់ឋានៈ ព្រមទាំងប្រជារាស្ត្រគ្រប់ប្រភេទក្នុងប្រទេស បានទទួលនូវសុខភាពនិងវឌ្ឍនភាពគ្រប់ប្រការ តាំងពីក្នុងបច្ចុប្បន្នកាលនេះតរៀងទៅ ! ។

## សេចក្តីថ្លែងការណ៍ថ្វាយ
## របស់ព្រះតេជព្រះគុណ ទុំ - អ៊ុម

បន្ទាប់ពីនោះមកទៀត ព្រះតេជព្រះគុណ ទុំ - អ៊ុម មេគណវត្តយាយទេពខេត្តកំពង់ឆ្នាំង បានថ្លែងសុន្ទរកថា ក្នុងនាមនៃមន្ត្រីសង្ឃទាំងឡាយ ដែលមានសេចក្តីប្តេជ្ញាចំពោះព្រះប្រមុខមហាក្សត្រថានឹងព្រមធ្វើតាមព្រះរាជឱង្ការទាំងអស់ ដូចតទៅនេះ ។

សូមថ្វាយព្រះពរព្រះករុណា ម្ចាស់ជីវិត

សូមទ្រង់ជ្រាប ។

អាត្មាភាព តាងនាមមន្ត្រីសង្ឃគ្រប់តំណែងដែលបានមកកាន់អនុសំវច្ឆរៈសន្និបាត ជាគំរប់ ៧ ហើយដែលបានមកប្រជុំក្នុងទីនេះ សូមព្រះរាជទានព្រះរាជវរោកាសថ្វាយយោបល់ ដោយសេចក្តីគោរពដ៏ក្រៃលែងចំពោះព្រះពុទ្ធសាសនានិងចំពោះព្រះករុណាជាអម្ចាស់ជីវិត ដោយសេចក្តីថ្លែងការណ៍ថ្វាយដូចខាងក្រោមនេះ ។

អាត្មាភាពទាំងឡាយ ទោះបីសព្វថ្ងៃនេះ ប្រទេសខ្មែរកើតមានអសន្តិភាពនៅទីតំបន់ខ្លះ មិនបរិបូណ៌ដោយសន្តិភាពក៏ដោយ ឥតមានផាកប្រែចិត្តគំនិត សូម្បីបន្តិចបន្តួច អំពីសេចក្ដីជឿកាន់ នឹងសេចក្ដីស្មោះត្រង់ ព្រមទាំងស្វាមីភក្ដិ ចំពោះព្រះករុណាជាអម្ចាស់ជីវិត នឹងសេចក្ដីគោរព ដោយទទួលជឿស្ដាប់តាមព្រះយោបល់នៃព្រះករុណាជាអម្ចាស់ជីវិត អាត្មាភាពទាំងឡាយក៏បានបំពេញហើយ ហើយនឹងខំប្រឹងបំពេញឲ្យសព្វគ្រប់ តាមកំឡាំងរៀងកាល់រូបតរៀងទៅ ព្រោះរំពឹងយល់ឃើញហើយជឿច្បាស់ថា ត្រូវតែអាត្មាភាពទាំងឡាយ នាំគ្នាហែតាមក្រោយព្រះករុណាជាអម្ចាស់ជីវិត ព្រះប្រិយមហាក្សត្រិយ៍ដែលមានព្រះយោបល់ នឹងនយោបាយដ៏ផ្សេងៗ ពីនោះផ្ទុយស្រឡះឆ្ងាយពីគ្នាណាស់ នឹងអាចញ៉ាំងប្រទេសជាតិនឹងព្រះពុទ្ធសាសនាឲ្យលូតលាស់ចំរើនទៅមុខពុំបាន ៗ បានដឹងកាលគ្នាថាព្រះករុណាជាអម្ចាស់ជីវិតទ្រង់សានព្រះរាជហឫទ័យ ទ្រង់ព្រះមេត្តាប្រោសដល់អស់ប្រជានិករ ដោយតាំងព្រះរាជហឫទ័យប្រកបដោយករុណា ទ្រង់ព្រះស្ដិតនៅជាសុខក្នុងព្រះសិរីរាជសម្បត្តិតទៅ ដោយលះលាកចាកសេចក្ដីទៀយណាយ ទោះអាត្មាភាពទាំងឡាយព្រមទាំងប្រជាជនពលរដ្ឋមានសោមនស្សដ៏ក្រៃលែង ដោយមានសង្ឃឹមពេញមាំថា កម្ពុជរដ្ឋនឹងបានរួចចាកគ្រោះថ្នាក់ផុតឧបសគ្គផ្សេងៗ ហើយនឹងមានវឌ្ឍនភាពស្ថាពរ

ដោយសារព្រះយោបល់និងវីរិយភាពដ៏ប្រសើរ នៃព្រះករុណាជាម្ចាស់ជីវិតជាប្រមុខរបស់រដ្ឋ ។ គុណនៃសីលធម៌ណា ដែលអាត្មាភាពរាល់រូបព្រមទាំងសិស្សគណ និងពុទ្ធបរិស័ទទាំងឡាយជាចំណុះវត្តនីមួយៗ ក្នុងកម្ពុជរដ្ឋទាំងមូល បានប្រព្រឹត្តប្រតិបត្តិតាមលំអានព្រះពុទ្ធសាសនា, សូមគុណនៃសីលធម៌នោះ ជួយអភិបាលរក្សាព្រះករុណាជាអម្ចាស់ជីវិតព្រមទាំងសម្តេចព្រះបរមរាជបិតា និងសម្តេចព្រះវររាជជននីនាថ ទាំងពីរព្រះអង្គ នៅព្រះរាជវង្សានុវង្ស អង្គអគ្គសេវកាមាត្យមុខមន្ត្រីគ្រប់តំណែង ! សូមមានសិរីសួស្តីជ័យជំនះគ្រប់ទិសទី ! សូមឲ្យប្រទេសកម្ពុជារួចផុតស្រឡះចាកគ្រោះថ្នាក់ឧបសគ្គទាំងពួង ! ហើយសូមឲ្យបានលូតលាស់ចម្រើនតាមកាលសម័យ ប្រកបដោយសន្តិភាពរៀបរយគអន្លង់វែងឆ្ងាយទៅ ! ។

ពិធីនេះបានបញ្ចប់ដោយធម៌ជយន្តោ ដែលពួកមន្ត្រីសង្ឃបានស្វាធ្យាយ, រួចព្រះរាជាទ្រង់បានប្រគេនទូវសៀវភៅវិន័យនិងសៀវភៅនិយាយពីរឿងត្រៃចីវរចំពោះព្រះសង្ឃ ។

នៅពេលថ្ងៃត្រង់ មានការលៀងភត្តចំពោះមន្ត្រីសង្ឃនិងលោកគ្រូចៅអធិការទាំងនោះនៅវត្តឧណ្ណាលោម ដោយការបរិច្ចាគនៃព្រះរាជទ្រព្យនិងការបរិច្ចាគនៃមន្ត្រីក្រសួងធម្មការ ជាមួយនិងឧបាសកឧបាសិកាទាំងឡាយ ។